# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែមិថុនា លេខ៦

ព.ស.២៤៩៨ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង


| ផ្នែកសាសនា | | ទំព័រ |
| --- | --- | --- |
| —វិចារណកថា ................ | លោកប៊ូ-ប៊ូ ........... | ៣២៣ |
| —អត្ថានុវត្តកថា ................ | ព្រះអាចារ្យ ផេង-សុន្ទរ .... | ៣៣១ |
| —រឿងមាណពអ្នកឈ្លាសក្នុងស្នាមជើង ... | ឃុនសិរីមេធី ស្រី-អ៊ូ ...... | ៣៣៩ |
| —បញ្ញាសជាតក ភាគទី ៣ (តមក) .... | បណ្ឌិតមហា ឈឹម-ស៊ុម .... | ៣៥៥ |

ផ្នែកអក្សរសាស្ត្រ

| | | |
| --- | --- | --- |
| —រឿងសៅរ៍សោយ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... | ៣៦២ |
| —រឿងសាមកុក (តមក) .......... | ឧកញ៉ា នូ-កន ......... | ៣៦៨ |
| —ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) ... | លោក ផេង-ជ្រីវ ........ | ៣៧៧ |
| —រឿងបល្ល័ង្កទិព្យ (តមក) .......... | លោក ប៉ាយ-ប៊ុក ........ | ៣៨៣ |

កំណត់ទីផ្សេងប្រវត្តិការណ៍

| | | |
| --- | --- | --- |
| —បុណ្យឆ្លង ព្រះវិហារនិងសាលាបឋមសិក្សា នៅវត្តសិរីបទុម (វត្តអន្លង់ស) ស្រុកកងមាស កំពង់ចាម ................ | លោក ចាប-ពិន ......... | ៣៩១ |



មួយឆ្នាំមាន ១២ សៀវភៅ — ជំនៀជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


PARTIE RELIGIEUSE:

| | | Page |
|---|---|---|
| — Editorial . . . . . . . . . | Vén. NOU-SOK . . . . . . . | 323 |
| — Attanurakkhakatha . . . . . | Vén. PHENG-SON . . . . . | 331 |
| -- Padakusalajataka . . . . . . | M. SREY-OU . . . . . . . . | 339 |
| — Pannasajataka- vol.3 (suite) . | M. CHHIM-SOUM . . . . . | 355 |

PARTIE LITTERAIRE:

| | | |
|---|---|---|
| — Le «SAU SOY» ou l'influence saturnienne (suite) . . . . . | Vén. PEUNG-PAM . . . . . | 362 |
| — Histoire de samkok (suite) . . | Oknha NOU-KAN . . . . . . | 368 |
| — Le souffle du désert (suite) . . | M. PHENG-CHRIV . . . . . | 377 |
| — Les trente deux récits du Trône (suite) . . . . . . . . | M. RAY-BUC . . . . . . . . | 383 |

NOTES ET CHRONIQUES:

| | | |
|---|---|---|
| — Inauguration du temple et de l'Ecole Primaire à Vat Siripaduma . . . . . . . . . . . | M. CHAP-PIN . . . . . . . | 391 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

# សាសនាទុកជាថ្នាំប្រចាំជីវិត

សាសនាគឺពាក្យប្រៀនប្រដៅ ដែលជាគោលរបស់ចិត្ត អាចគ្រប់គ្រងចិត្តរបស់អ្នករាប់អានកាន់តាមឲ្យជ្រះថ្លា ឲ្យវៀរចាកវត្ថុដែលគួរវៀរ ឲ្យធ្វើវត្ថុដែលគួរធ្វើ ឲ្យសម្រេចការគ្រប់គ្រងខ្លួនដោយខ្លួនឯង ឲ្យដឹងខុសត្រូវអាក្រក់ល្អដោយខ្លួនឯង ។

សាសនាជារបស់ចាំបាច់យ៉ាងវិសេស មានដម្លៃលើសលុប ដែលមនុស្សគ្រប់ឋានៈ ត្រូវមាន ត្រូវរាប់អានប្រចាំចិត្តខានពុំបាន ព្រោះសាសនាជាអណ្ដូងទឹកកើតនៃសីលធម៌ ជាគ្រឿងនាំសេចក្ដីសុខមកឲ្យអ្នកកាន់តាម ដូចដំណក់ទឹកភ្លៀងដែលធ្លាក់ចុះមក នាំយកទាំងសេចក្ដីរីករាយមកផង ។ សាសនាជាប្រទីបព្រោលបំភ្លឺចិត្តមនុស្ស ឲ្យជីវភាពមនុស្សមានដំណើរល្អ ឲ្យយោគយល់ចិត្តថ្លើមមនុស្សផងគ្នា, មិនឲ្យបៀតបៀនគ្នាដោយផ្លូវត្រង់ទឹងផ្លូវអម ។ សាសនាជាគ្រឿងគ្រប់គ្រងមនុស្សបានទាំងផ្លូវកាយ ផ្លូវចិត្ត ទាំងទីកំបាំង ទីវាល យ៉ាងជិតស្និទ្ធល្អ ជាងច្បាប់គ្រប់គ្រងមនុស្សដែលបានត្រឹមតែកងកាយម្យ៉ាង ចំណែកចិត្តគ្រប់គ្រងមិនបាន, ច្បាប់ដាក់ទោសមនុស្សអ្នកប្រព្រឹត្តល្មើសបានតែក្នុងពេលដែលចាប់កំហុសបាន ដោយមានសាក្សី ឬមានឯកសារជាកស្តុតាង; តែបើមនុស្សអ្នកប្រព្រឹត្តល្មើសនោះលបធ្វើក្នុងទីកំបាំង ចាប់មិនបានទេ ព្រោះគ្មានសាក្សីគ្មានឯកសារជាឡាក់ឋាន ។ ឯមនុស្សអ្នករាប់អាន

សាសនា មានសាសនាត្រឿងប្រចាំចិត្ត តែងមានចិត្តអៀនខ្មាសមិនហ៊ាន ធ្វើអំពើអាក្រក់ សូម្បីក្នុងទីកបាំងដែលគ្មានអ្នកណាដឹងឃើញឡើយ ។ មនុស្សគ្រប់រូប គ្រប់ភេទ គ្រប់វ័យ សុទ្ធតែត្រូវការសេចក្ដីសុខស្ងប់ ដូចគ្នា គ្មានអ្នកណាបដិសេធថា មិនត្រូវការនោះទេ ។ ឯសេចក្ដីសុខ ស្ងប់គ្រប់យ៉ាងនោះឯង គឺជាផលកើតមកអំពីគោលធម៌នៃសាសនា ។

ធម្មតាចិត្តមនុស្ស រមែងអន្ទះអន្ទែងស្ទុះស្ទាទៅកាន់អារម្មណ៍ផ្សេងៗ ដែលចូលមកប្រលោមឲ្យស្រឡាញ់ខ្លះ មកញុះញង់ឲ្យស្អប់ខ្ពើមខ្លះ មក លំលួងឲ្យភ្ញាំងភ្ញាក់ញាប់ញ័រខ្លះ មិនឲ្យនៅនឹងនួនបាន បើគ្មានបង្គោលឲ្យ ចិត្តប្រកាន់យកជាបង្អែក ចិត្តរមែងមិននឹងធឹងនៅបានទេ តែងតែអណ្ដែត អណ្ដូងទៅរកសេចក្ដីក្ដៅក្រហាយ ដូចស្វាដែលចូលចិត្តលោតចុះលោត ឡើង បើមិនចងទុកនឹងបង្គោលបណ្ដោយឲ្យទៅតាមទំនើង អាចនឹងធ្វើឲ្យ វិនាសច្រើនស្ថាន ។ ចិត្តរបស់មនុស្សរមែងត្រូវវិបត្តិដោយអំណាច សេចក្ដីលោភ, ក្រោធ, វង្វេង, តណ្ហា, ឫស្យា ព្រមទាំងឲ្យទោស គឺសេចក្ដីវិនាស អាក្រក់ ខ្លាំងជាងសេះដែលខូច ឬជាងដីរបុះប្រែងទៅ ទៀត ។ ដោយហេតុនេះមនុស្សយើង ត្រូវមានគោលគឺសាសនាជាបង្អែក ជាគ្រឿងអប់រំចិត្ត ដើម្បីឲ្យប្រណីតបញ្ចូលលះបង់សេចក្ដីវិបត្តិអាក្រក់ នោះចោលចេញ ។ មនុស្សដែលមានសាសនាជាគោលហ្វឹកហាត់ចិត្ត រមែងគ្មានសេចក្ដីវិបត្តិ មានតែសេចក្ដីត្រជាក់ចិត្ត ឥតកិលេសដុតពេល ឲ្យធ្វើសេចក្ដីអាក្រក់ ដែលជាហេតុឲ្យក្ដៅក្រហាយឲ្យវិនាសដល់ខ្លួននឹង អ្នកដទៃទេ ។ ចំណែកមនុស្សដែលគ្មានសាសនា ឈ្មោះថា គ្មានគោល

គ្មានបង្អែក ចិត្តមនុស្សដែលគ្មានបង្អែក រមែងត្រូវវិបត្តិនិងត្រូវក្រសែកិលេសនាំទៅតាមយថាកម្ម ដូចជាទូកដែលគ្មានបង្គោលចង រមែងត្រូវខ្សែទឹកនិងខ្យល់បក់ឲ្យរសាត់ទៅរកទីបំផុតគ្មាន អាចបណ្ដាលឲ្យអន្តរាយលិចលង់ក្នុងពេលណាមួយ ឬដូចរថយន្ត ដែលគ្មានហ្វ្រាំងជាគ្រឿងទប់កង់ អាចនឹងជ្រុលទៅបុករថយន្តដូចគ្នា ឬមនុស្ស ឲ្យខូចឲ្យមានរបួស ឬឲ្យអន្តរាយដល់ជីវិតបាន ។

ម្យ៉ាងទៀត សាសនាទុកដូចជាគ្រឿងអលង្ការដ៏មានតម្លៃ សម្រាប់តាក់តែងចិត្តរបស់មនុស្សឲ្យល្អ ឬក៏ដូចជាសម្លៀកបំពាក់ សម្រាប់បិទបាំងរាងកាយ ឲ្យសុខសប្បាយ ឲ្យកក់ក្ដៅ អាចការពារក្ដៅត្រជាក់បានតាមត្រូវការ, មនុស្សដែលគ្មានគ្រឿងអលង្ការនិងសំលៀកបំពាក់សូម្បីបន្តិចបន្តួចសម្រាប់បិទបាំងរាងកាយ រមែងជាទីគួរអៀនខ្មាសនិងគួរខ្ពើមរបស់អ្នកដែលបានជួបបានឃើញ កាលត្រូវសេចក្ដីក្ដៅរងាមកប៉ះពាល់ ក៏រមែងមានទុក្ខវេទនាទ្វេឡើងទៀត, គ្មានសុខស្រួលឡើយ, ចំណែកមនុស្សអ្នកមានសំលៀកបំពាក់ និងគ្រឿងអលង្ការតាក់តែងរូប-កាយ រមែងសមរម្យល្អគួរទស្សនា សូម្បីក្ដៅត្រជាក់មកប៉ះពាល់ខ្លាំងយ៉ាងណា ក៏គ្រឿងសំលៀកបំពាក់នោះអាចជួយការពារឲ្យបានសុខស្រួល ។ មនុស្សគ្មានសាសនាជាគ្រឿងប្រដាប់ចិត្ត មិនផ្សេងគ្នាពីមនុស្សដែលអាក្រាតកាយនៅតែខ្លួនទទេនោះឡើយ, ហើយចិត្តមនុស្សបែបនោះ រមែងមិនល្អ មិនមានសេចក្ដីសុខស្ងប់, កាលបើកិលេសា-សវៈចូលញាំញីក៏រឹតតែមួម៉ៅក្ដៅក្រហាយខ្លាំងឡើងទៀត ។ មនុស្ស

អ្នកមានសាសនាប្រចាំចិត្ត រមែងមានចិត្តល្អបរិសុទ្ធ មានចិត្តត្រជាក់ត្រជុំ នៅជាសុខ សូម្បីកិលេសចូលមកញាំញីខ្លាំងយ៉ាងណា ៗ ក៏សាសនា អាចជួយការពារមិនឲ្យក្ដៅក្រហាយបាន ។

ដោយហេតុនេះ មនុស្សអ្នកយល់ត្រូវតាមគន្លងធម៌មិនវិបល្លាស ចាកហេតុផល ទើបគេនាំគ្នានិយមកាន់សាសនា ដើម្បីទុកជាអលង្ការ និងជាគោលចិត្ត មិនបណ្ដោយចិត្តរបស់គេឲ្យអណ្ដែតទៅតាមក្រសែនៃ សេចក្ដីអាក្រក់ដែលចូលមកប្រលោមលោមលួងឲ្យភ្លេចខ្លួន, ហើយចិត្ត របស់ជនដែលមានសាសនាជាបង្អែក រមែងចំរើនដោយសេចក្ដីល្អ គ្មាន សេចក្ដីថោកទាបទេ ដូចដើមឈើដែលដុះល្អមាំមួនរឹងប៉ឹងឡើង ក៏ព្រោះ មានឫសកែវជាកម្លាំង ។ សាសនាអាចធ្វើអំណោយសន្ដិសុខនិង ប្រយោជន៍ដល់មនុស្សគ្រប់សញ្ជាតិ គ្រប់វណ្ណៈ ឲ្យតែអ្នកណាប្រតិបត្តិ តាមគោលធម៌ក្នុងសាសនា អ្នកនោះក៏បានសេចក្ដីត្រជាក់សុខស្រួលនិង បានទទួលប្រយោជន៍តាមសមគួរដល់ការប្រតិបត្តិខ្លួនទៅគ្រប់គ្នា។ ដូច អាកាសដ៏បរិសុទ្ធ អ្នកណាបានស្រូបចូល អ្នកនោះក៏មានសុខភាព ស្រួល ។ ហេតុនេះសាសនាទើបមាននៅជាគូនឹងលោក ធ្វើឲ្យលោក មានសន្ដិសុខ, ជាគូនឹងប្រទេសជាតិ ធ្វើឲ្យប្រទេសជាតិបានចំរើនរុងរឿង, ជាគូនឹងពួកមនុស្ស ធ្វើឲ្យពួកមនុស្សស្រឡាញ់រាប់អានគ្នា យល់ចិត្ត ថ្លើមគ្នា, ជាគូនឹងពួកគណៈ ធ្វើឲ្យពួកគណៈមានសាមគ្គីគ្នាជានិច្ច, ដូចដួងព្រះអាទិត្យព្រះចន្ទមាននៅជាគូនឹងអាកាសផែនដី ព្រមទាំងលោក ខានពុំបាន ។

បើសាសនា មាននៅជាគួនឹងលោកអាចធ្វើអំណោយសន្តិភាពដល់លោកជាអនេកប្បការយ៉ាងនេះ, ចុះហេតុដូចម្តេចក៏មានជនខ្លះយល់ខុសថា សាសនាជាថ្នាំដែលញៀនហើយឲ្យពោសផង? តាមសេចក្តីពិត បើពោលតាមហេតុផល ក៏គង់ឃើញថា សាសនាមិនមែនជាថ្នាំដែលញៀនហើយឲ្យពោសសោះឡើយ, ប្រសិនបើប្រៀបសាសនាទៅនឹងថ្នាំក៏ជាថ្នាំដែលគួរសេព មិនមែនជាថ្នាំដែលញៀនហើយឲ្យពោសទេ ។ ដោយមានហេតុផលដូច្នេះ ទើបគួរញែកថ្នាំជា ២ យ៉ាងគឺ ថ្នាំគួរសេព ១ ថ្នាំមិនគួរសេព ១ ។ ថ្នាំគួរសេព គឺថ្នាំដែលចាំបាច់ដល់ជីវិតពិតៗ ខានមិនបាន វៀរចាកមិនកើត, ក្នុងវេលាមានឈឺថ្កាត់ដូចជាគ្រុន, ឈឺក្បាល, ក្តៅខ្លួន, ឬរណ្តាពេក (របេង) យើងត្រូវបរិភោគថ្នាំ ដូចជាអាស្ពីរីន, គីនីន ឬថ្នាំចាក់ជាដើម ដើម្បីបំបាត់រោគទាំងនោះឲ្យជាសះស្បើយទៅ ។ ថ្នាំបែបនេះជាថ្នាំចាំបាច់ពិតប្រាកដដែលយើងត្រូវសេព ។ បុគ្គលណាមានរោគហើយមិនបរិភោគថ្នាំកែរោគ បណ្តោយឲ្យប្រព្រឹត្តទៅតាមយថាកម្ម រោគក៏មិនសះស្បើយ បុគ្គលនោះក៏ត្រូវរងទុក្ខវេទនាយ៉ាងខ្លាំងគ្មានសេចក្តីសុខស្រួលទេ ក្នុងទីបំផុតអាចនឹងដល់នូវសេចក្តីស្លាប់បាន ។ បុគ្គលណាមានរោគហើយបានបរិភោគថ្នាំកែរោគ បុគ្គលនោះ មិនបានឈ្មោះថា បរិភោគថ្នាំដែលញៀនទេ បានឈ្មោះថាជាអ្នកបរិភោគថ្នាំដែលគួរបរិភោគ ហើយបានសេចក្តីសរសើរថាជាអ្នកចេះថែរក្សាខ្លួនផង ។

ចំណែកវត្ថុដែលមិនមែនជាថ្នាំចាំបាច់ដល់ជីវិតមនុស្ស  បានខាង បារី កញ្ឆា ស្រា និងអាភៀនជាដើម ទោះបីមិនសេពក៏មិនក្តៅក្រហាយ ថែមទាំងអាចជម្ពុលជីវិតឲ្យរស់នៅបានតាមប្រក្រតី, តែមនុស្សខ្លះផ្តើម ហាត់សេពស្រា កញ្ឆា បារី ឬអាភៀន ដែលជារបស់មិនចាំបាច់នោះ ធ្វើឲ្យញៀនជាប់ កើតជាការចាំបាច់ឡើង ម្ល៉ោះហើយអត់មិនបាន ក៏ត្រូវការសេពរឿយៗទៅ ។ វត្ថុបែបនេះអាចកើតជាទោស ព្រោះធ្វើអ្នកសេពឲ្យញៀនជាប់នាំឲ្យសាប់សល់ក្រវល់ក្រវាយ ក្នុងពេលមិនបានសេព តែកាលបានសេពក៏បន្ធូបង់សេចក្តីសាប់សល់បានតែមួយខណៈ រួចកើតសេចក្តីសាប់សល់ទៀត ជាហេតុធ្វើឲ្យសេពតទៅទៀតរកទីបំ-ផុតគ្មាន ហើយជាហេតុឲ្យអ្នកផងតិះដៀលថា មិនសមបើទៅហាត់ខ្លួនឲ្យជាប់ចំពាក់ ដោយវត្ថុមិនមែនជារបស់ចាំបាច់នោះឡើយ ។ ចំណែកផ្លូវសាសនា ដែលពោលថាជាឱសថគួរសេពនោះ ក៏ព្រោះថាមនុស្សក្នុងលោកនេះ បើមិនសេពថ្នាំគឺសាសនា គ្មានសាសនាប្រចាំចិត្តទេ ក៏គ្មានហិរិឱត្តប្បៈ គឺគ្មានសេចក្តីអៀនខ្មាសក្នុងចិត្ត និងគ្មានសេចក្តីកោតក្រែងចំពោះសេចក្តីអាក្រក់គ្រប់យ៉ាងឡើយ លោកក៏មិនត្រជាក់ត្រជុំសុខស្រួល និងមិនយល់ចិត្តថ្លើមគ្នានិងគ្នា មានតែការបៀតបៀនបំផ្លិចបំផ្លាញគ្នាទៅវិញទៅមក ដោយគ្មានមេត្តាករុណា ប្រហែលគ្នានឹងសត្វព្រៃដែលកាចសាហាវ មិនមានសេចក្តីអៀនខ្មាស ហ៊ានធ្វើសេចក្តីអាក្រក់ទាំងក្នុងទីកាលទាំងក្នុងទីកំបាំង ដោយឥតញញើតដល់បាបកម្មឡើយ, លោកនឹងមានសភាពដែលគួរឲ្យតក់ស្លុតហួសប្រមាណ

ដូចជាបានព្រះគរវែសញ្ញា (សាវ៉ែន) ប្រាប់មហន្តរាយតាមផ្លូវអាកាស ឬដូចជាមនុស្សមានរោគហើយមិនបរិភោគថ្នាំកែរោគ រោគនោះក៏នៅពាំវ៉ែកក្នុងខ្លួនជានិច្ច, លុះតែបានបរិភោគថ្នាំដែលគួរបរិភោគទៅកាលណា ទើបរោគនោះជាសះស្បើយទៅបាន ។

សាសនាអាចធ្វើមនុស្សឲ្យចេះរក្សាសេចក្ដីស្ងប់រៀបរយបានល្អ ឲ្យចេះយល់ចិត្តថ្លើមគ្នា ជួយអើពើកិច្ចការដល់គ្នានឹងគ្នា ឲ្យចេះយកចិត្តទុកដាក់ចំពោះគ្នីគ្នា ឲ្យដឹងគុណឧបការៈរបស់អ្នកមានគុណ ហើយគប់ស្នងសងគុណលោក តាមកម្លាំងដែលអាចធ្វើបាន ទោះមានឱកាសល្មមនឹងប្រព្រឹត្តអំពើអាក្រក់បានក៏មិនធ្វើ ព្រោះមានសាសនាប្រចាំចិត្តធ្វើឲ្យចេះអៀនខ្មាសចំពោះអំពើអាក្រក់នោះ ៗ ដោយន័យនេះទើបឃើញថាសាសនាប្រៀបធៀបទៅនឹងថ្នាំ គឺជាថ្នាំគួរសេពពិតប្រាកដ ព្រោះកាលណាសេពហើយ តែងធ្វើអ្នកសេពឲ្យមានសេចក្ដីសុខយ៉ាងត្រជាក់ត្រជុំ រំលត់ទុក្ខវេទនាគ្រប់យ៉ាងឲ្យអស់ទៅបាន ដូចជាថ្នាំកែរោគដែរ, តែសាសនាមិនមែនជាថ្នាំញៀនជាប់ដូចជាមនុស្សបំពូកខ្វះយល់ខុសនោះទេ ព្រោះវត្ថុដែលញៀនជាប់នោះមិនមែនជារបស់ចាំបាច់ដល់ជីវិតមនុស្សឡើយ តែមនុស្សទេតើដែលទៅហាត់សេពឲ្យជាប់ខ្លួនឯងរហូតដល់កើតជារបស់ចាំបាច់ឡើង, ចំណែកសាសនាជាថ្នាំចាំបាច់ដល់ជីវិតមនុស្សពិត ៗ បើមនុស្សគ្មានសាសនានៅប្រចាំក្នុងចិត្តទេ ក៏បានឈ្មោះថា ជាមនុស្សតែពាក់កណ្ដាលប៉ុណ្ណោះ ព្រោះចិត្តមិនខ្ពស់ជាងសត្វតិរច្ឆានឡើយ ហើយជាមនុស្ស គ្រាន់តែមានកមានក្បាលដូចមនុស្ស

តែមិនដឹងឧបការគុណអ្នកណាឡើយ, ដោយហោចទៅ សូម្បីមាតាបិតាបង្កើតខ្លួន ក៏ថាគ្មានឧបការគុណដែរ ។ ចំណែកសាសនាខ្លះទូន្មានចិត្តមនុស្សឲ្យដឹងគុណអ្នកមានគុណ ដែលហៅថាកតញ្ញូ ហើយឲ្យតបស្នងសងគុណលោកដែលហៅថាកតវេទី ។ សាសនាមាននាទី ជួយលើកដំកើងមនុស្សភាព ឲ្យមានលក្ខណៈពេញជាមនុស្សមែនទែនឲ្យមានសេចក្ដីថ្លៃថ្នូរ ឲ្យមានចិត្តខ្ពស់ជាងសត្វតិរច្ឆាន ។

ហេតុដូច្នេះ មនុស្សក្នុងលោកគ្រប់រូប ទើបគួរសេពសាសនា គឺគួរមានសាសនាប្រចាំនៅក្នុងចិត្ត ។

ព្រះមហា ឆួរ-សុខ

## គួរចងស្ពានមេត្រីនឹងអ្នកមានត្រកូលស្មើគ្នា

មនុស្សពីរនាក់ណា មានទ្រព្យសម្បត្តិប៉ុនគ្នា មានត្រកូលប៉ុនគ្នា មនុស្សពីរនាក់នោះ ត្រូវចងមេត្រីនឹងគ្នា ត្រូវធ្វើវិវាហៈជាមួយគ្នា តែឯមនុស្សម្នាក់ខ្សោយម្នាក់ទៀតខ្លាំង គេមិនត្រូវធ្វើ គឺមិនត្រូវចងស្ពានមេត្រីទេ ។

ម្រឹគត្រូវគប់មួយអន្ទើដោយម្រឹគទាំងឡាយ គោដោយគោទាំងឡាយ សេះដោយសេះទាំងឡាយ មនុស្សល្ងង់ដោយមនុស្សល្ងង់ទាំងឡាយ អ្នកប្រាជ្ញដោយអ្នកប្រាជ្ញទាំងឡាយ, ការចងគ្នាជាសំឡាញ់បានចំពោះតែមនុស្សណា បើល្អ ល្អដូចគ្នា ឬបើអាក្រក់ អាក្រក់ដូចគ្នាទេ ។

បញ្ញត្ត្រ:

# ផ្នែកសាសនា

## អត្តានុរក្ខកថា

ព្រះអាចារ្យ ផេង-សុគ្ន័រ វត្តកែវព្រះភ្លើង ភ្នំពេញ

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយគោរព) ។

វេលានេះ អាត្មាភាពសូមសំដែងអំពីសុភាសិត ១ កន្ទេង ដែលព្រះបរមលោកនាថទ្រង់សំដែងមានក្នុងគម្ពីរធម្មបទដ្ឋកថា ជាធម្មស្សវនាការដល់ពុទ្ធបរិស័ទ្យទាំងឡាយ ដូចតទៅនេះ

មុននឹងលើកយកពុទ្ធភាសិតនោះមកសំដែង សូមនាំយកបុគ្គលាធិដ្ឋានមកសំដែងជាខាងដើមសិន ដើម្បីនឹងអធិប្បាយដំកលទៅរកពុទ្ធភាសិត ដែលប្រុងនឹងយកមកសំដែងក្នុងឱកាសនេះ ។

សេចក្តីដំណាលថា កាលព្រះបរមសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន, កាលនោះ មានភិក្ខុទាំងឡាយជាច្រើនរូប បានទៅនៅចាំវស្សាក្នុងបច្ចន្តប្បទេស ភិក្ខុទាំងនោះបាននៅជាសុខស្រួល ក្នុងខែជាដំបូង, តែលុះដល់ខែជាបន្ទាប់មក មានពួកចោរចូលមកប្លន់ស្រុកសម្រាប់គោចររបស់ភិក្ខុទាំងនោះ ហើយចាប់យកអ្នកស្រុកធ្វើជាឈ្លើយដោយច្រើន លំដាប់តមក ពួកអ្នកនគរទាំងឡាយក៏រវល់តែនឹងប្រុងប្រៀបរៀបចំការពារនគរ

មិនបានឧបត្ថម្ភដល់ភិក្ខុទាំងឡាយ ៗ ក៏នៅដោយលំបាក, លុះចេញវស្សាហើយ ក៏នាំគ្នាចូលទៅបង្គំគាល់ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សួរសុខទុក្ខនៃភិក្ខុទាំងឡាយនោះ តាមទម្លាប់នៃបដិសណ្ឋាររបស់ព្រះអង្គ ៗ ភិក្ខុទាំងឡាយ ក៏ក្រាបទូលតាមហេតុនោះដោយសព្វគ្រប់, លុះទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ត្រាស់អនុលោមតាមពាក្យភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ! ការនៅជាសុខស្រួលអស់កាលជានិច្ច គេរកបានដោយកម្រណាស់, ហេតុនេះពួកមនុស្សដែលប្រុងប្រយ័ត្នចាត់ពិធីថែរក្សាការពារនគរយ៉ាងណាមិញ អ្នកទាំងឡាយក៏ត្រូវប្រុងប្រៀបរៀបចំថែរក្សាខ្លួនយ៉ាងនោះដែរ" រួចទ្រង់សំដែងពុទ្ធភាសិតនេះថា

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ
ឯវំ គោបេថ អត្តានំ ខណោ មា វោ ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា

"(ម្នាលភិក្ខុទាំងឡាយ) ពួកមហាជនគេប្រុងរក្សាការពារនគរដែលតាំងនៅក្នុងទីបំផុតនៃដែនទាំងខាងក្នុងទាំងខាងក្រៅ យ៉ាងណាមិញ; អ្នកទាំងឡាយ ក៏ត្រូវប្រុងថែរក្សាខ្លួន យ៉ាងនោះដែរ, ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះថា សត្វទាំងឡាយ ដែលបណ្ដោយឲ្យខណៈកន្លងហួសទៅហើយ រមែងសោយសោកពេញណែនក្នុងនរក" ។

ព្រះពុទ្ធភាសិតខាងលើនេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះតែនឹងពួកភិក្ខុក៏ពិតមែនហើយ តែតាមព្រះពុទ្ធបំណងមិនមែនដូច្នោះទេ គឺព្រះពុទ្ធ-

ភាសិតនេះជាសាធារណៈទូទៅដល់បរិស័ទទាំងឡាយ ឥតរើសមុខ ។ ឯសេចក្ដីសំខាន់ក្នុងផ្ទៃនៃគាថានេះ ចែកជា ៣ ផ្នែក គឺ:

១– ត្រូវថែរក្សាខ្លួន ឲ្យដូចជាពួកមហាជនប្រុងប្រយ័ត្ន រក្សាការពារនគរ ។

២– ខណៈ កុំប្រព្រឹត្តកន្លងនូវអ្នកទាំងឡាយ ។

៣– បើសត្វទាំងឡាយ បណ្ដោយឲ្យខណៈកន្លងហួសទៅ រមែងសោយសោកពេញណែនក្នុងនគរ ។

ទី ១– ត្រង់ថា "ត្រូវថែរក្សាខ្លួន ឲ្យដូចជាពួកមហាជនប្រុងប្រយ័ត្នរក្សាការពារនគរ" នោះ បានសេចក្ដីថា ត្រូវដំកល់សតិ (រឭក) ទីងពិនិត្យការពារចំពោះទ្វារទាំង ៦ គឺ: ចក្ខុទ្វារ ១, សោតទ្វារ ១, ឃានទ្វារ ១, ជិវ្ហាទ្វារ ១, កាយទ្វារ ១, មនោទ្វារ ១. ព្រោះសពាង្គកាយរបស់សព្វសត្វទាំងឡាយ ប្រៀបដូចនគរមានទ្វារ ៦ គឺ មានចក្ខុទ្វារជាដើមនោះឯង, មានព្រះមហាក្សត្រមួយព្រះអង្គសោយរាជ្យក្នុងនគរនោះ ពោលគឺព្រះបាទចិត្តរាជ, ឯអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ប្រៀបដូចជាអាគន្តុកៈ (អ្នកដំណើរ) តែងសញ្ចរចូលមកក្នុងនគរគឺពាងកាយ តាមទ្វារទាំងឡាយមានចក្ខុទ្វារជាដើម, សតិប្រៀបដូចជាទ្វារបាល (អ្នកយាមទ្វារ) សម្រាប់ត្រួតពិនិត្យនូវរូបារម្មណ៍ជាដើម ដែលតែងត្រាច់ចូលមកតាមចក្ខុទ្វារជាដើមនោះឲ្យដឹងថាល្អ ឬ អាក្រក់, បើដឹងថាអាក្រក់ ក៏បដិសេធចេញ ឬ រាំងមិនឲ្យចូលក្នុងព្រះនគរនោះ, បើដឹង

ថាល្អ ក៏បណ្ដោយឱ្យចូល ឬ ក៏នាំពត៌មាននេះមកថ្វាយព្រះបាទចិត្តកជឱ្យទ្រង់ជ្រាបជាមុន, បើទ្រង់អនុញ្ញាតឱ្យចូល ក៏ចូល បើមិនទ្រង់អនុញ្ញាតទេ ក៏អាក់ខាន; ព្រោះអារម្មណ៍ទាំងនោះ តែងធ្វើឱ្យព្រះបាទចិត្តកជបានសុខក៏មាន ទុក្ខក៏មាន, ចំរើនក៏មាន វិនាសក៏មាន, ដោយអំណាចនៃរូបារម្មណ៍លោកចែកជា ២ យ៉ាង គឺៈ រូបនាំមកនូវសុខ ១, រូបនាំមកនូវទុក្ខ ១, សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍, និងធម្មារម្មណ៍ ក៏សុទ្ធតែចែក ២ យ៉ាងដូចគ្នាដែរ ។ ហេតុដូច្នេះ បើបុគ្គលបានប្រទះនូវអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមណាមួយដែលជាសុខ ចំរើននោះ គប្បីដំកល់សតិការពារ-ទប់សោមនស្ស ឬបដិពទ្ធចិត្ត ដែលជាហេតុនាំឱ្យកើតតណ្ហាចំពោះអារម្មណ៍នោះ, បើបានប្រទះនូវអារម្មណ៍ដែលជាទុក្ខ ទោស ឬ នាំឱ្យវិនាស គប្បីដំកល់សតិញុំាងមេត្តាចិត្តឱ្យកើតឡើង, កុំគប្បីមានបដិឃៈ ឬ ព្យាបាទចិត្តចំពោះអារម្មណ៍នោះឡើយ ។

បុគ្គលណាមួយ បានដំកល់សតិសង្រួមចក្ខុទ្វារជាដើម ការពារនូវអារម្មណ៍ទាំងពីរប្រការ ដូចន័យដែលអធិប្បាយមកនេះហើយ សមគួរថាជាអ្នកបានរក្សាការពារខ្លួនដោយប្រពៃ, អាចនឹងបាននូវសុខភាពនិងវឌ្ឍនភាពក្នុងលោកនេះ និងលោកខាងមុខ ពុំលែងឡើយ ។

ទី ២ ត្រង់ថា "ខណៈកុំប្រព្រឹត្តកន្លងនូវអ្នកទាំងឡាយ" នេះជាពាក្យ គឺ ព្រះសម្ពុទ្ធទ្រង់ត្រាស់ដាស់រំឭកពុទ្ធបរិស័ទទាំងឡាយ កុំឱ្យស្ថិតនៅក្នុងបមាទធម៌ ព្រោះបមាទធម៌នេះ ចូលជ្រកជោកជាំក្នុង

សន្តានថៃបុគ្គលណាហើយ បុគ្គលនោះនឹងខកខានមិនបានគុណសម្បត្តិសមត្ថភាព ឬ គំបណ្ដាយឲ្យខណៈនោះកន្លងហួសទៅពុំបាន ។ ឯខណៈនោះលោកចែកចេញជា ៤ យ៉ាងគឺ:

១– ពុទ្ធុប្បាទក្ខណោ ខណៈដែលព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកម្ដងៗ ចាត់ថាជាខណៈ ដែលសត្វសត្វទាំងឡាយ ត្រូវបានទទួលមហគ្គតគុណដ៏អស្ចារ្យ មានសោតាបន្នភាពជាដើម តាមឧបនិស្ស័យរៀងៗខ្លួន ប្រាណ ពុំនោះសោតនឹងបានទទួលទិដ្ឋធម្មិកផល ដូចយ៉ាងទុគ្គតបុរសជាដើម, ព្រោះព្រះសព្វញ្ញុពុទ្ធទ្រង់ជានេយ្យានិកបុគ្គល តែងហ្វឹកហ្វឺនយឹតយោងពុទ្ធវេនេយ្យសត្វ ដែលមានឧបនិស្ស័យល្មមព្រះអង្គប្រោសបាន ឲ្យយល់ច្បាស់ក្នុងឧបាយនៃការសន្សំប្រយោជន៍ក្នុងលោកនេះនឹងបរលោក ជាបច្ចល់សត្វអាចញាំងកិលេសនឹងតណ្ហាឲ្យរីងស្ងួតហើយរំលត់ខាន់ចូលទៅកាន់អមតនិព្វានជាបរិយោសាន ។

២– មជ្ឈិមប្បទេសេ ឧប្បត្តិក្ខណោ ខណៈដែលសត្វបានកើតក្នុងមជ្ឈិមប្រទេស ជាខណៈដ៏អស្ចារ្យ គួរសត្វប្រាថ្នាចង់ទៅកើត ព្រោះប្រទេសនោះជាទីកើតនៃរតនៈ ៧ ប្រការ មានព្រះបច្ចេកពុទ្ធជាដើម, នឹងព្រះពុទ្ធមាតាពុទ្ធបិតាជាដើម ។ កាលបើព្រះពុទ្ធបានត្រាស់ហើយ ពួកមហាជនទាំងឡាយក្នុងមជ្ឈិមប្បទេសនោះ បើទំនៃជាអ្នកស្ថិតនៅក្នុងអរិយធម៌ដ៏ប្រសើរមានទិដ្ឋិសីលជាដើមដោយបរិបូណ៌ ជាសត្វមានឧបនិស្ស័យ ល្មមឈោងចាប់យកនូវឧត្តមភាព នឹងសុខភាពបាន ។

៣– សម្មាទិដ្ឋិយា បដិលទ្ធក្ខណោ ខណៈដែលសត្វបានចំពោះនូវសម្មាទិដ្ឋិ គឺការៈនៃបញ្ញាចេតសិកយល់ត្រូវថា ទុក្ខទាំង ១២ កងជាទុក្ខមែន, តណ្ហាជាហេតុនាំឲ្យកើតទុក្ខ, ការបន្សាត់បង់នូវតណ្ហាបាន ជាឧបាយនាំឲ្យរលត់ទុក្ខ, ការប្រតិបត្តិតាមអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ពុំនោះសោត យល់ចំពោះហេតុនិងផលក្នុងកាលទាំង ៣ គឺៈ បច្ចុប្បន្ន, អតីត· អនាគត, ទាំងអាចប្រកបកិច្ចសព្វយ៉ាង ដើម្បីញុំាងភាពនៃខ្លួនឲ្យឡើងកាន់វិវដ្ដធម៌បាន ។

៤– ឆន្នមាយតនានំ អវិកលក្ខណោ ខណៈដែលសត្វមានអាយតនៈ មិនខ្វះខាត គឺមាន ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត, កាយ, ចិត្ត, ពេញបរិបូណ៌ជាបុរិសភាព ឥត្ថិភាព, ហៅថាជាខណៈរបស់សត្វមានភ័ព្វដ៏ប្រសើរ, ព្រោះថាសត្វទាំងឡាយ បើមានអាយតនៈណាមួយខ្វះខាតហើយ មិនអាចប្រកបកិច្ចសព្វយ៉ាងឲ្យកើតឡើងដោយពេញបរិបូណ៌បានឡើយ ។ ហេតុនេះ សត្វដែលមានអាយតនៈពេញបរិបូណ៌ ហៅថាជាសត្វមានភ័ព្វដ៏ប្រសើរនោះ មិនគួរធ្វេសប្រណ្ដាយឲ្យខកខានសិក្សាចំណេះវិជ្ជាមានអក្សរសាស្ត្រ, ការ្យសាស្ត្រជាដើម និងមិនគួរខកខានបំពេញកុសលផ្សេងៗ ដែលជានាថករណីយកិច្ច ក្នុងបច្ចុប្បន្នសម័យនឹងកាលជាអនាគតឡើយ ។

ទី ៣ ត្រង់ថា "បើសត្វទាំងឡាយ បណ្ដោយឲ្យខណៈកន្លងហួសហើយរមែងសោយសោកពេញណែនក្នុងនរក" នោះ សព្ទថា "នរក"

ប្រែថា "ទីនាំចេញនូវសេចក្ដីសុខ" គឺថាសោយសុទ្ធតែទុក្ខ, ឬប្រែថា "រណ្ដៅ" បើចែកតាមឈ្មោះមាន ៨ គឺៈ សញ្ជីវៈ ១, កាលសុតៈ ១, សង្ឃាដៈ ១, រោរវៈ ១, មហារោរវៈ ១, តាបៈ ១, មហាតាបៈ ១, អវីចិ ១, ។ តែក្នុងឱកាសនេះ សូមអធិប្បាយតាមទេវទូតសូត្រ ដែលព្រះបរមគ្រូទ្រង់សំដែងអំពីអវីចិនរក ទីនរកជាបន្ទាប់ ៗ ។ អវិចិ សព្ទនេះប្រែថា "គ្មានចន្លោះ" សំដៅគ្មានចន្លោះពីរយ៉ាងគឺ គ្មានចន្លោះសត្វ គឺថាក្នុងអវីចិនរកទាំងមូលពេញណែន ដោយសត្វនរកឥតមានចន្លោះ ១ គ្មានចន្លោះភ្លើង គឺថាក្នុងនរកនោះមានអណ្ដាតភ្លើងឆាបឆេះជានិច្ចឥតចន្លោះ ១, អវីចិនរក មានសណ្ឋានដូចជាហិប, មានទ្វារ ៤ តាមលំដាប់ទិស, កំពស់ជញ្ជាំងឡើង ៩ យោជន៍, ទំហំជុំវិញទាំងអស់ ១០០ យោជន៍, សត្វដែលកើតក្នុងនរកនោះ សោយទុក្ខដោយអណ្ដាតភ្លើងដ៏សន្ធោសន្ធៅឆាបឆេះជានិច្ចឥតមានពេលស្រាក ។ បន្ទាប់អំពីអវីចិនរកទៅ មានគូថនរក មួយរណ្ដៅទៀត ក្នុងនរកនោះពេញណែនដោយលាមកទាំងអស់ សត្វដែលកើតក្នុងនរកនោះមានលាមកជាអាហារៈ មានដង្កូវបុន ៗ អណ្ដើក តែងចោះ ឬ ជញ្ជក់យករសជាតិក្នុងខ្លួនសត្វនរកនោះ សត្វក្នុងនរកនោះដែលកើតស្លាប់ ៗ ដោយអំណាចដង្កូវចោះ ឬជញ្ជក់នោះឯង ។ បន្ទាប់អំពីគូថនរកនោះទៅ មានកុក្កុឡនរក មួយរណ្ដៅទៀត ក្នុងនរកនោះពេញណែនដោយផេះក្ដៅទាំងអស់ សត្វតែងសោយទុក្ខដោយអំណាចផេះក្ដៅនោះ ។ បន្ទាប់អំពីកុក្កុឡនរកនោះទៅ មានសិម្ពលីនរក (រកាដែក) ដើមរកាដែក

នោះមានបន្ទាស្រួចៗ ប្រវែង ១៦ អង្គុលី មានភ្លើងឆេះព្រោលផ្លោតផត ចន្ទោះ, ពួកនិរយបាលតែងវាយបង្ខំសត្វណាដែលមានទោសឲ្យឡើង ដើមរការដែកនេះ ដោយឥតត្រាប្រណី ។ បន្ទាប់អំពីសិម្ពលីនរកនោះ ទៅ មានព្រៃសសិត មួយទៀត សត្វសោយទុក្ខក្នុងនរកនោះដោយ អំណាចខ្យល់បក់ស្លឹកសសិតមកប៉ះលះដាច់សាច់អង្កាន់ៗ ដូចគេអង្កាន់ត្រី ។ បន្ទាប់អំពីព្រៃសសិតនោះទៅមានស្ទឹងទឹកក្រុត ១ ទៀត សត្វក្នុងនរកនោះ ខ្វះក៏អត់អាហារ ១ ពុទ្ធន្តរ ឬ ២ ពុទ្ធន្តរមកហើយ មានកាលម្តងៗ ពួក និរយបាលយកសន្ទូចមក់ស្ទូច សត្វនរកក៏ស៊ុះទៅត្របាក់ដោយស្មាន ថាជាចំណី, និរយបាលទាត់សន្ទូចឡើងយកមកលើគោកហើយសួរថា: "ឯងឃ្លានអ្វី?" ។ —"ខ្ញុំឃ្លានអាហារណាស់!"; ។ និរយបាលក៏យកដុំ ដែកដែលភ្លើងកំពុងឆេះព្រោលផ្លោ បញ្ចុកក្នុងមាត់សត្វនរកនោះ, ហើយ ក៏សួរទៀតថា "ឯងត្រូវការអ្វីទៀត?" ។ —"ឱ! លោកអើយ ខ្ញុំស្រេក ទឹកណាស់!" ។ និរយបាលក៏ដងទឹកទង់ដែងដែលកំពុងពុះ មកច្រកក្នុង មាត់សត្វនរកនោះ ម្ល៉ោះហើយក៏សោយទុក្ខវេទនាកតណានាពុំបាន ។

បើបុគ្គលបានដឹងច្បាស់តាមន័យដែលបានអធិប្បាយមកនេះហើយ គួរប្រុងប្រយ័ត្នចាត់ពិធីថែរក្សាការពារខ្លួន កុំឲ្យខណៈកន្លងហួសទៅ ដោយមិនបានប្រកបកិច្ចមានការបំពេញកុសលជាដើម ដរាបដល់ធ្លាក់ខ្លួន ទៅកាន់ហីនភាព ក្នុងលោកនេះ និងបរលោកដោយបមាទធម៌ឡើយ ។

អាត្មាភាពសំដែងធម៌នេះល្មមដល់វេលានឹងបញ្ចប់ហើយ, សូម សន្និបកថា ដោយនូវប្រការអម្បាលណោះ ឯង ។

# រឿងមាណពអ្នកឈ្លាសក្នុងស្នាមជើង

បទកុសលជាតក ក្នុងជាតកដ្ឋកថា នវកនិបាត

## ឃុនសិរីមេធ ស្រី-អ៊ូ ប្រែ

---

កាលព្រះបរមគ្រូទ្រង់គង់ក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់សំដែងប្រារព្ធកុមារម្នាក់ដែលជាកូនកុដុម្ពីក៍ នៅក្នុងក្រុងសាវត្ថីថាៈ

កុមារនោះមានអាយុ ៧ ឆ្នាំគត់ អាចស្គាល់ស្នាមជើងពិតប្រាកដ មិនដែលមានភ័ន្តច្រឡំសោះ ។ ពេលមួយបិតាចង់ល្បងមើលដំរិះកូន ក៏លបដើរទៅលេងផ្ទះញាតិ មិនឲ្យកុមារនោះដឹងខ្លួនឡើយ ។ លុះយូបន្តិច កុមារនោះរកមើលបិតាមិនឃើញ ក៏ឈ្ងោកមើលស្នាមជើង ហើយតាមរកបិតាទៅទាន់ឯផ្ទះញាតិ ។ បិតាសួរៈ នៃកូន ហេតុដូចម្ដេច ក៏អ្នកដើររកឃើញ ។ កូនឆ្លើយៈ ខ្ញុំស្គាល់ស្នាមជើង ។ សម័យថ្ងៃមួយ បិតាចេញដើរបំបាត់ជើងយ៉ាងឆ្ងាយ គឺដើរចូលទៅក្នុងផ្ទះអ្នកស្និទ្ធស្នាលហោៗទៅ ហើយគេចចេញទៅខាងជើងព្រះនគរបត់ចូលមកអង្គុយស្ដាប់ធម៌ព្រះសាស្ដាក្នុងវត្តជេតពន ។ គ្រានោះកុមារសួររកបិតា, អ្នកផងប្រាប់ថា យើងមិនដឹងទេ កុមារឆាករកមើលស្នាមជើង ហើយដើរតាមហោៗទៅទាន់បិតា កំពុងអង្គុយស្ដាប់ធម៌ ។ បិតាសួរ ហេតុអ្វីក៏អ្នកដឹងថាយើងមកក្នុងទីនេះ ។ កុមារឆ្លើយៈ ខ្ញុំស្គាល់ស្នាមជើង ។ បិតាស្ងើចនឹងកូន ហើយសរសើរថា កូននេះតូចប៉ុណ្ណោះទេ ក៏ចេះអ៊ីម្ល៉េះ ។

ពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្បែរនោះ បានប្រាប់សព្វដំណើរ ហើយទ្រង់មានព្រះពុទ្ធដីកាថា ម្នាលឧបាសក ការស្គាល់ស្នាមជើងនៅលើផែនដីនេះ មិនទាន់ជាអស្ចារ្យប៉ុន្មានទេ កាលបុរាណ-បណ្ឌិតជាន់ដើម គេអាចស្គាល់ស្នាមជើងឮដ៏អាកាសបាន ហើយទ្រង់នាំអតីតនិទានថា ។

ក្នុងកាលកន្លងទៅហើយ អគ្គមហេសីរបស់ព្រះបាទព្រហ្មទត្ត ក្នុងក្រុងពារាណសី ប្រព្រឹត្តកន្លងព្រះទ័យព្រះរាជស្វាមី ទៅខូចនឹងបុរសម្នាក់ ។ ព្រះរាជាមានព្រះទ័យរង្កៀសទ្រង់ចាប់ពិរុទ្ធសួរបញ្ជាក់ ។ អគ្គមហេសីនោះស្បថថ្វាយព្រះរាជាថា "បើខ្ញុំម្ចាស់ប្រព្រឹត្តកន្លងព្រះទ័យព្រះអង្គមែន ដល់ខ្ញុំម្ចាស់ស្លាប់ទៅ សូមឲ្យទៅកើតជាយក្ខិនី មានមុខជាសេះចុះ" ។ លុះអគ្គមហេសីនោះធ្វើមរណកាល ក៏ទៅកើតជាយក្ខិនី មានមុខជាសេះមែន, កែងនៅអាស្រ័យក្នុងគុហាមួយ ចាំចាប់ពួកមនុស្សដែលដើរដោយផ្លូវព្រៃមកបរិភោគ ។

មានសេចក្តីដំណាលថា យក្ខិនីនោះបានអំណាចពីស្តេចវេស្សវ័ណ កំណត់ទីទទឹងចម្ងាយ ៣០ យោជន៍ បណ្តោយ ៤០ យោជន៍ ។ ថ្ងៃមួយមានព្រាហ្មណ៍មានទ្រព្យសម្បត្តិច្រើន នាំពួកបរិវារដើរទៅត្រង់ទីនោះ ។ យក្ខិនីក្រឡេកឃើញ ក៏ស្ទុះដេញចាប់ព្រាហ្មណ៍នោះបាន, ឯពួកបរិវារនាំគ្នារត់រួចអស់ ។

យក្ខិនីក៏ព្រនាក់ព្រាហ្មណ៍នោះលើខ្នង យកទៅទីកន្លែងរបស់ខ្លួន ។ ដោយអំណាចកិលេសបណ្តាលឡើង ក៏ស្រឡាញ់ព្រាហ្មណ៍នោះត្រឡប់

ជាមិនបរិភោគ បែរជាយកធ្វើជាប្តីរួមសង្វាសជាមួយគ្នាវិញ ។ តាំងពីពេលនោះមក យក្ខិនីចាប់បានមនុស្សឯទៀត យកតាំងសំពត់ទឹងអង្គរជាដើម មកចិញ្ចឹមប្តី ។ នាងយក្ខិនីពេលដែលចេញទៅរកអាហារ តែងភ័យខ្លាចប្តីរត់ចោល ក៏យកថ្មមកខ្ទប់គុហាទើបចេញទៅ ។ កាលព្រាហ្មណ៍នឹងយក្ខិនីនៅរួមសង្វាសជាមួយគ្នា ព្រះពោធិសត្វក៏ចុះមកចាប់បដិសន្ធិក្នុងផ្ទៃយក្ខិនីនោះ លុះគ្រប់ ១០ ខែប្រសូតចេញមក ។ យក្ខិនីស្រឡាញ់កូននោះខ្លាំងណាស់ ឲ្យកូននៅតែក្នុងគុហា មិនឲ្យដើរទៅទីណាឡើយ ។ លុះកូននោះធំដឹងក្តីសព្វគ្រប់ សួរបិតាថា បពិត្របិតា ហេតុដូចម្តេចបានជា មុខអ្នកម្តាយដោយឡែក មុខលោកឪពុកដោយឡែក មិនប្រហែលគ្នាសោះ ។ បិតាប្រាប់ថា នែកូន ម្តាយបាឯងជាយក្ខិនី តែងស៊ីសាច់មនុស្ស បាឯងនឹងយើងជាមនុស្ស ។ កូននិយាយថា បើដូច្នោះយើងនឹងនៅក្នុងទីនេះធ្វើអ្វី ! សូមអញ្ជើញទៅឯស្រុកមនុស្សវិញ ។ បិតានិយាយថា កូន ! បើយើងរត់ទៅ មុខជាម្តាយបាឯងសម្លាប់យើងទាំងពីរនាក់មិនខានទេ ។ កូនឆ្លើយថា បពិត្របិតា សូមបិតាកុំខ្លាច ខ្ញុំធានានាំបិតាទៅឲ្យដល់ស្រុកមនុស្ស ។

សម័យមួយ កូននោះដឹងថា យក្ខិនីចេញទៅរកអាហារហើយក៏ច្រានថ្មបើកទ្វារនាំបិតាចេញមកលេងខាងក្រៅ ដល់យក្ខិនីត្រឡប់មកវិញ ឃើញទ្វារបើកទើបសួរថា នរណាបើកទ្វារ ។ កូនឆ្លើយតបថា អ្នកម្តាយ ! ខ្ញុំមិនចង់អង្គុយក្នុងទីងងឹតទេ បានជាខ្ញុំបើកទ្វារចេញមក ។ យក្ខិនីមិនមានស្តីបន្ទោសអ្វីឡើយ ដោយអំណាចស្រឡាញ់កូន ។ លុះ

យូរបន្តិចមក កូននោះក៏នាំបិតារត់ចេញមកស្រុកមនុស្ស ។ យក្ខិនីវិលមកវិញមិនឃើញកូននឹងប្ដី ក៏ស្ទុះទៅតាមទាន់និយាយថា បពិត្រអ្នកជាប្ដី ប្ដីក៏អ្នករត់ចោលខ្ញុំ អ្នកចង់បានអ្វី? ។ ព្រាហ្មណ៍ឆ្លើយថា ម្នាលប្អូនស្រី នាងកុំខឹងនឹងបង កូននាងនាំបងរត់មកទេតើ ។ យក្ខិនីក៏មិនប្រកាន់ទោសអ្វីឡើយ រួចនាំមកកន្លែងរបស់ខ្លួនវិញ ។ ព្រាហ្មណ៍នឹងកូននាំគ្នារត់យ៉ាងនេះអស់ ៣ លើក ។ យក្ខិនីចេះតែតាមទាន់យកមកវិញ ។ ពេលមួយ កូននោះគិតរកឧបាយនឹងរត់ឲ្យរួច ទើបទៅអង្គុយឱបម្ដាយហើយសួរថា បពិត្រអ្នកម្ដាយ សូមអ្នកម្ដាយប្រាប់ទីព្រំប្រទល់ត្រើមណា ដែលអ្នកម្ដាយផ្សាយអំណាចទៅបាន ទីត្រើមនោះហើយដែលជាកេរ្តិ៍មតិកត្រូវបានកូន សូមប្រាប់ខ្ញុំឲ្យដឹងផង ។ យក្ខិនីប្រាប់ទីព្រំប្រទល់មានក្នុងនឹងស្ទឹងជាដើមគ្រប់ទិសថា ទទឹងចម្ងាយ ៣០ យោជន៍ បណ្ដោយ ៥០ យោជន៍ កូនឯងចូរចំណាំទីប៉ុណ្ណោះទុកចុះ ។ លុះកន្លងមកពីរបីថ្ងៃ យក្ខិនីចេញទៅស្វែងរកអាហារ កូនក៏បញ្ជិះបិតាលើកខ្លួនរត់ចេញទៅដល់ឆ្នេរស្ទឹងប្រទល់ដែន ។ ឯយក្ខិនីត្រឡប់មកវិញមិនឃើញប្ដីនឹងកូន ស្ទុះរត់ដេញតាមឃើញកូនកំពុងតាប់ដឹកដៃបិតាចុះទៅក្នុងស្ទឹង ។ យក្ខិនីដឹងថា ផុតដែនរបស់ខ្លួនហើយ ក៏ឈរនិយាយអង្វរប្ដីនឹងកូនថា នែកូនប្រុស អ្នកចូរនាំបិតាមកវិញ បពិត្រប្ដី ខ្ញុំប្រតិបត្តិខុសត្រង់ដូចម្ដេច សូមអ្នកអត់ទោស សូមអញ្ជើញមកវិញ ។ លំដាប់នោះ ព្រាហ្មណ៍ចេះតែដើរទៅខាងនាយ មិនត្រឡប់មកវិញសោះ ។ យក្ខិនីនិយាយទៅរកកូនថា ម្នាលកូនស្ងួន អ្នកកុំធ្វើយ៉ាងហ្នឹង ចូរកូនអ្នក

វិលមកវិញ ៗ កូនប្រកែកថា ខ្ញុំជាមនុស្ស អ្នកម្ដាយជាយក្ខិនីស៊ីតែសាច់មនុស្ស ខ្ញុំមិនហ៊ានទៅជាមួយទេ ៗ យក្ខិនីអស់សេចក្ដីសង្ឃឹមហើយ តែនឹកអាណិតកូនខ្លាំងណាស់ ទើបនិយាយប្រាប់កូនថា កូនអើយ ! ការចិញ្ចឹមជីវិតក្នុងមនុស្សលោកនេះលំបាកណាស់ ក្រណាស់ បើមិនចេះសិល្បវិជ្ជាអ្វីហើយ មិនងាយនឹងចិញ្ចឹមជីវិតបានស្រួលទេ ម្ដាយចេះវិជ្ជាមួយឈ្មោះចិន្ដាមណី (១) វិជ្ជានេះមានអានុភាព អាចស្គាល់ស្នាមជើងចោរ ដែលលួចទ្រព្យគេចំនួន ១២ ឆ្នាំហើយ គង់តាមរកឃើញចាប់បានទាំងចោរមកផង ហេតុនេះ កូនឯងចូររៀនមន្ដនេះចុះ គ្រាន់នឹងចិញ្ចឹមជីវិត ៗ កូនក៏ឈរសំពះម្ដាយក្នុងស្ទឹង ប្រឹងរៀនមន្ដនោះដរាបទល់ចប់ ទើបនិយាយថា សូមអ្នកម្ដាយអញ្ជើញទៅវិញចុះ ៗ យក្ខិនីឆ្លើយតបដោយពាក្យជាគាថា ថា:

ឯហិ បុត្ត និវត្តស្សុ មា អនាថំ ករោហិ មេ
អជ្ជ បុត្តំ អបស្សន្តី យក្ខិនី មរណំ គតា ។

ហៃកូនប្រុសពន្លក ចូរវិលមកឆាប់ ៗ ពី
អ្នកកុំឲ្យមាតា អនាថាណាមាសថ្លៃ
កាលបើមិនឃើញបា ខ្លួនមាតានឹងក្សិណក្ស័យ
ស្លាប់ក្នុងវេលាថ្ងៃ នេះពុំខានទេកូនអើយ ៗ

យក្ខិនីបែកទ្រូងស្លាប់ក្នុងទីនោះ ; កូនដឹងថាមាតាស្លាប់ហើយ ទើប

---

១ - វិជ្ជាដូចជាកែវមណី អាចសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាងតាមចិត្តនឹកបាន ។

នាំបិតាទៅលើកសពបូជានាឆេរស្ម័ន រួចនាំបិតាទៅក្រុងពារាណសី ។ ចូលទៅឈរក្បែរទ្វារប្រាសាទស្តេចហើយឲ្យគេទៅក្រាបទូលថា មានមាណពម្នាក់ ជាអ្នកឈ្លាសស្គាល់នូវស្នាមជើង ឥឡូវនេះនៅឈរក្បែរទ្វារប្រាសាទ ។ ព្រះរាជាទ្រង់មានព្រះរាជឱង្ការថា បើដូច្នោះ ត្រូវឲ្យវាចូលមក ។ មាណពក៏ចូលទៅគាល់ព្រះរាជា, ព្រះរាជាទ្រង់សួរថា នែមាណព អ្នកឯងចេះមន្តវិជ្ជាពិតមែនឬ ។ — ព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំជាខ្ញុំចេះមន្ត អាចស្គាល់ស្នាមជើងចោរ ដែលលួចទ្រព្យគេចំនួន ១២ ឆ្នាំហើយ គង់តាមរកឃើញ ចាប់បានទាំងចោរមកផង ។ — អើ បើដូច្នោះ មាណពឯងត្រូវនៅបំរើយើង ៗ នឹងឲ្យមួយពាន់កហាបណៈរាល់ៗថ្ងៃ ។ — ព្រះករុណាថ្លៃវិសេស ។ ថ្ងៃមួយបុរោហិតក្រាបទូលថា បពិត្រមហារាជ ព្រះអង្គមិនទាន់ជ្រាបមន្តវិជ្ជារបស់មាណពនេះសោះ ដឹងជាចេះមែនឬមិនចេះទេ សូមព្រះអង្គល្បងមើលសិន ។ ព្រះរាជាយល់តាមបុរោហិត ទើបយាងទៅជាមួយនឹងបុរោហិត ទៅយកកែវព្រះរាជទ្រព្យក្នុងប្រាសាទ ហើយយាងទៀលផ្លាត់កាត់ព្រះរាជនិវេសន៍ ៣ លើក ទើបពាក់បង្អួងឡើងកំពែងចូលទៅក្នុងព្រះទីនាំងវិនិច្ឆ័យគង់បន្តិច យាងចុះទៅប្រទក្សិណស្រះក្នុងព្រះរាជបុរី ៣ ជុំ ដើម្បីនឹងបំបាត់ដាន ទើបយាងចុះទៅលាក់កែវព្រះរាជទ្រព្យក្នុងស្រះ ទ្រង់ឡើងមកគង់ក្នុងប្រាសាទវិញ ។ លុះព្រឹកឡើងកើតជ្រួលច្របល់ថា យប់មិញចោរលួចយកកែវព្រះរាជទ្រព្យអំពីប្រាសាទបាត់ហើយ ។ ព្រះរាជាធ្វើហាក់ជាមិនជ្រាប ទ្រង់ត្រាស់ហៅមាណពមកថា អ្នកឯងរកឃើញ

ប្ដទេ ៗ – ក្រាបទូលគេឃើញ ប៉ុនអម្បាលចោរលួចដល់ ១២ ឆ្នាំហើយ ទូលព្រះបង្គំជាខ្ញុំគង់គេឃើញ ៗ – បើដូច្នោះអ្នកឯងទៅយកមក ៗ មាណពចេញទៅឈរនៅមុខព្រះលានលើកដៃសំពះនឹកគុណម្ដាយ តាំងពយមន្ត នឹកសញ្ជឹងបន្តិច ទើបក្រាបទូលថា បពិត្រមហារាជ នេះពិតជាចោរពីរនាក់ ដើរចូលទៅក្នុងប្រាសាទ ចេញពីនោះមកចុះដើរត្រៀលធ្លាក់ក្នុងព្រះរាជនិវេសន៍ ៣ លើក រួចពាក់បង្អោងឡើងកំពែងចូលទៅក្នុងព្រះទីនាំងវិនិច្ឆ័យ ទើបចុះទៅប្រទក្សិណស្រះ ៣ ជុំ យកកែវព្រះរាជ-ទ្រព្យទៅលាក់ក្នុងស្រះនោះ ៗ ក្រាបទូលដូច្នេះហើយ ក៏ចុះទៅយកកែវព្រះរាជទ្រព្យមកថ្វាយព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ចោរពីរនាក់នេះ សុទ្ធតែមានកេរ្តិ៍ឈ្មោះល្បីល្បាញ ឥឡូវនេះ ឡើងមកអង្គុយក្នុងព្រះរាជនិវេសន៍នេះ ៗ មហាជនត្រេកអររីករាយទះដៃឈូឆរ លើកទង់ជ័យព្រោងព្រាត ៗ ព្រះរាជាទ្រង់ត្រាស់ថា អើ បើអ្នកឯងរកកែវព្រះរាជទ្រព្យឃើញហើយ ត្រូវចាប់ចោរមកឲ្យយើងទៀត ៗ – បពិត្រមហា-រាជ ចោរនៅក្បែរហ្នឹង មិនមែននៅឆ្ងាយទេ ៗ – បើដូច្នោះ ឯងត្រូវចាប់មកបង្ហាញយើង ៗ – បពិត្រព្រះម្ចាស់ផែនដី ព្រះអង្គឃើញកែវព្រះរាជទ្រព្យហើយតើ សូមព្រះអង្គកុំចង់បានចោរទៀត ៗ – នៃមាណពយើងឲ្យមួយពាន់កហាបណៈរាល់ ៗ ថ្ងៃដល់អ្នកឯង ត្រូវតែអ្នកឯងចាប់ចោរមកឲ្យយើង ៗ – បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំមិនហ៊ានថ្វាយឈ្មោះចោរដល់ព្រះអង្គទេ ប៉ុន្តែសូមនាំរឿងមួយមកថ្វាយព្រះអង្គ ៗ គង់ជ្រាបបាន ទើបនាំអតីតនិទានថា:

បពិត្រមហារាជ ក្នុងកាលដែលកន្លងទៅហើយ មានអ្នករបាំម្នាក់ ឈ្មោះបាដលី តែងនៅអាស្រ័យក្នុងស្រុកតូចមួយប្របឆ្នេរស្ទឹងជិតក្រុងពារាណសី ។ ថ្ងៃមួយអ្នករបាំនោះ នាំប្រពន្ធទៅលេងមហោស្រពឯក្រុងពារាណសី បានរង្វាន់យ៉ាងច្រើន, ដល់ពេលឈប់លេង នាំប្រពន្ធចេញមក ក៏ទិញស្រានិងបាយយកទៅផ្ទះរបស់ខ្លួន លុះដល់ឆ្នេរស្ទឹង ឃើញទឹកហូរថ្មីៗ ឈប់អង្គុយបរិភោគបាយផឹកស្រា ស្រវឹងមិនដឹងខ្លួន ក៏យកតាប៉ុមកចងក ដឹកដៃប្រពន្ធចុះស្ទឹង ទឹកហូរចូលតាមរន្ធតាប៉ុ ពន្លិចអ្នករបាំនោះក្នុងស្ទឹង ។ ប្រពន្ធដឹងថា ប្ដីលង់ទឹកហើយក៏លែងដៃប្ដី ស្ទុះមកលើគោក ប្ដីមុជងើបៗ ទឹកចូលពេញពោះ ប្រពន្ធស្រែកសុំចម្រៀងប្ដីថា បពិត្រអ្នកប្ដីអើយ សូមអ្នកច្រៀងចម្រៀងប្អូនបានមួយបទគ្រាន់ទ្រង ចិញ្ចឹមជីវិត ។ ប្ដីឆ្លើយថា ហៃប្អូនស្រី បងនឹងឲ្យចម្រៀងដូចម្ដេចកើត បើទឹកកំពុងតែចូលមាត់ មនុស្សយើងរស់នឹងទឹក ឥឡូវនេះទឹកសម្លាប់ហើយ ភ័យទៅជាកើតមកអំពីរបស់ដែលជាទីពឹង ។ បពិត្រមហារាជ ទឹកជាទីពឹងរបស់មហាជន ភ័យបែរជាកើតមកអំពីទឹកជាទីពឹងនោះ យ៉ាងណា ស្ដេចទាំងឡាយជាទីពឹងរបស់មហាជន ភ័យបែរជាកើតមកអំពីស្ដេចទាំងឡាយ ក៏យ៉ាងនោះដែរ ភ័យនោះគ្មាននរណាការពារបានឡើយ ព្រះអង្គជាបណ្ឌិតស្រាប់ហើយ សូមទ្រង់ជ្រាបចុះ ។ — យើងមិនយល់ទេ អ្នកឯងត្រូវចាប់ចោរមកឲ្យយើង ។ — បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់រឿងមួយទៀតចុះ ។ មាណពក៏ដំណាលរឿងមួយទៀតថា:

ក្នុងកាលពីដើមមានស្ទូនថ្នាំងម្នាក់ នៅក្នុងស្រុកជិតក្រុងពារាណសីនេះ បានជីករណ្ដៅមួយយ៉ាងធំក្រៃញកក្ដុំ ថ្ងៃមួយស្ទូនថ្នាំងនោះកំពុងតែកើបដីយកទៅធ្វើការផង់ ស្រាប់តែភ្លៀងធ្លាក់មកយ៉ាងខ្លាំង ទឹកពេញរណ្ដៅ ដីបាក់ធ្លាក់មកត្រូវបែកក្បាលយំទួញថា

ជនទាំងឡាយសាបព្រោះពូជលើផែនដី ពួកសត្វតែង
អាស្រ័យនឹងផែនដី ឥឡូវនេះ ផែនដីបំបែកក្បាលអាត្មាអញ
ភ័យទៅជាកើតមកអំពីរបស់ដែលជាទីពឹងវិញ ៗ

បពិត្រមហារាជ ផែនដីជាទីពឹងពំនាក់របស់មនុស្ស ត្រឡប់ជាបំបែកក្បាលស្ទូនថ្នាំងវិញ យ៉ាងណា ធម្មតាស្ដេចក៏ជាទីពឹងពំនាក់របស់មនុស្សលោកទាំងមូល ត្រឡប់ទៅជាធ្វើចោរកម្មយ៉ាងនោះដែរ នរណានឹងការពារបាន បពិត្រព្រះសម្មតិទេព ព្រះអគ្គលម្មជ្រាបថាឈ្មោះណាជាចោរហើយ ៗ — នៃមាណព អ្នកឯងត្រូវចាប់ដឹកដៃមកឲ្យយើង ៗ មាណពមិនហ៊ាន ក្រាបទូលថា "ព្រះអង្គនេះឯងជាចោរ" ដូច្នេះទេ ដោយអំណាចសេចក្ដីគោរព ទើបនាំឧទាហរណ៍មួយទៀតថា

បពិត្រព្រះសម្មតិទេព ក្នុងកាលមុន មានបុរសម្នាក់នៅក្នុងនគរនេះ បុរសនោះឃើញភ្លើងឆេះផ្ទះ ស្ទុះចូលទៅជញ្ជូនយកទ្រព្យក្នុងផ្ទះ ស្រាប់តែទ្វារផ្ទះបិទជិត ផ្សែងហុយងងឹតស្លុប រកផ្លូវចេញមកវិញមិនរួច ភ្លើងឆេះពេលលោកនៅក្នុងផ្ទះ ស្រែកទ្រហោយំថា

អ្នកផងតែងចំអិនអាហារនឹងភ្លើង កំដៅរបស់ដែលត្រជាក់ឲ្យក្ដៅ

ទឹងភ្លើង ភ្លើងទៅជាឆេះខ្លួនអាត្មាអញ ភ័យទៅជាកើតមក
អំពីរបស់ដែលជាទីពឹង ។

បពិត្រមហារាជ មនុស្សម្នាក់ទុកដូចជាភ្លើងជាទីពឹងរបស់មហាជន ទៅជាលួចទ្រព្យគេវិញ សូមព្រះអង្គកុំសួររកចោរឡើយ ។ – នៃមាណព អ្នកឯងកុំរវសរវាងត្រូវតែចាប់ចោរមក ។ មាណពនាំឧទាហរណ៍មួយទៀតថា

បពិត្រព្រះសម្មតិទេព កន្លងកាលមុន មានបុរសម្នាក់ទទួលព្រះរាជ-ទានច្រើនហួស ទៅជាហល់ចាក់ច្រាស់បានសេចក្ដីទុក្ខលំបាកស្រែកត្អូញថា:

ជនទាំងឡាយតែងញុំាងអត្តភាពឲ្យរស់ ដោយសារបាយ
ឥឡូវនេះ បាយនោះ ទៅជាសម្លាប់អាត្មាអញ ភ័យទៅ
ជាកើតមក អំពីរបស់ដែលជាទីពឹង ។

បពិត្រព្រះនរិន្ទ្រ បុគ្គលម្នាក់ជាទីពឹងរបស់មនុស្សលោក ដូចជាបាយដែរ បែរទៅជាលួចទ្រព្យគេវិញ សូមព្រះអង្គទ្រង់ជ្រាបចុះ ។ – នៃមាណព អ្នកឯងត្រូវចាប់ចោរមកឲ្យយើង ។ មាណពនាំរឿងមួយមកទៀតថា

បពិត្រព្រះសម្មតិទេព កន្លងកាលពីដើម មានឈើមួយដើមដ៏ធំ បរិបូណ៌ដោយមែកទងស្ទុក ដុះនៅក្នុងព្រៃហិមពាន្តជាទីអាស្រ័យនៃសត្វស្លាបច្រើនពាន់ មែកឈើនោះសង្កត់គ្នាចេញផ្សែងឆេះជាភ្លើងធ្លាក់កំទេចមក បក្សីមួយជាធំជាងគេ ឃើញភ្លើងនោះក៏និយាយថា

បក្សីទាំងឡាយអាស្រ័យនឹងដើមឈើណា ដើមឈើនោះ
ទៅជាបញ្ចេញភ្លើង ម្នាលគ្នាយើងទាំងឡាយ អ្នកទាំង

ឡាយចូរគប់រក នូវទិសតាំងឡាយចុះ ក៏យទៅជាកើត មកអំពីរបស់ដែលជាទីពឹង ។

បពិត្រព្រះសម្មតិទេព ដើមឈើជាទីពឹងរបស់ពួកបក្សី យ៉ាងណា ស្ដេចជាទីពឹងរបស់ប្រជាជនយ៉ាងនោះដែរ កាលបើស្ដេចធ្វើទោសហើយ នរណានឹងការពារបាន សូមព្រះអង្គជ្រាបចុះ ។ – នៃមាណព អ្នកឯងត្រូវចាប់ទោសមក ។ មាណពនាំរឿងមួយមកទៀតថា

បពិត្រមហារាជ ក្នុងកាសិកគ្រាមនេះ មានត្រកូលម្នាក់មានកូនប្រុសតែមួយ លុះបិតាស្លាប់ទៅ មាតាក៏រៀបចំឲ្យមានប្រពន្ធ នាងនោះមុនដំបូងបេះផ្គត់ផ្គង់ម្ដាយក្មេកដោយមាំមួន ដល់ពេលក្រោយមកបែរទៅជាញុះញង់ពោលទោសម្ដាយក្មេកប្រាប់ប្ដីថា ខ្ញុំមិនចិញ្ចឹមម្ដាយអ្នកឯងទេ អ្នកត្រូវសម្លាប់គាត់ចោលទៅ ។ ប្ដីឆ្លើយថា ការសម្លាប់មនុស្សក្រណាស់ យើងនឹងសម្លាប់ដូចម្ដេចកើត ។ – នៃអ្នកប្ដី ដល់គាត់សម្រាន្តលក់ យើងសែងគាត់ទាំងគ្រែទៅទំលាក់ក្នុងស្ទឹងខាងលិចផ្ទះឲ្យក្រពើវាខាំស៊ីអស់ទៅ ។ – អើស្រួលហើយ ចុះម្ដាយនាងឯងសម្រាន្តត្រង់ណា ។ – គាត់សម្រាន្តជិតម្ដាយអ្នកឯងដែរ ។ – បើដូច្នោះនាងឯងយកខ្សែទៅចងគ្រែដែលម្ដាយអញសម្រាន្តឲ្យហើយទៅ សឹមមកប្រាប់អញ ។ ប្រពន្ធចងរួចហើយមកប្រាប់ប្ដី ។ ឆ្លើយថា ចាំពួកមនុស្សដេកលក់សិន ហើយធ្វើជានាំប្រពន្ធដេក លុះប្រពន្ធដេកលក់ លបទៅស្រាយខ្សែពីគ្រែម្ដាយរបស់ខ្លួន ទៅចងគ្រែរបស់ម្ដាយខាងប្រពន្ធវិញ ហើយមកដាស់ប្រពន្ធឲ្យទៅជួយសែងគ្រែ ប្រពន្ធក្រោកឡើងជួយសែង

ឲ្យគេទៅទំលាក់ក្នុងស្ទឹងខាងក្រោយផ្ទះ ក្រពើស៊ីយាយនោះអស់ ។ លុះព្រឹកឡើង ប្រពន្ធដឹងថា ប្តីផ្លាស់ប្តូរគ្រែដូច្នោះ ទៅនិយាយនឹងប្តីថា ឥឡូវនេះអ្នកសម្លាប់ម្តាយខ្ញុំហើយ ត្រូវអ្នកសម្លាប់ម្តាយអ្នកឯងទៀត ។ ប្តីឆ្លើយថា អើម្តងនេះ យើងត្រូវសែងទាំងគ្រែទៅដុតចោលឯព្រៃស្មសាន ទើបស្រួល ។ លុះម្តាយដេកលក់ នាំគ្នាប្តីប្រពន្ធសែងម្តាយទៅដល់ព្រៃស្មសាន ប្តីសួរថា ឯងបានយកភ្លើងមកដែរឬ ។ — ខ្ញុំមិនបានយកមកទេ ។ បើដូច្នោះឯងទៅយកមក អញនៅចាំ ។ — ខ្ញុំមិនហ៊ានទៅទេ ខ្លាចខ្មោច ។ — ឯងនៅចាំចុះ អញទៅយក ។ — ខ្ញុំមិនហ៊ាននៅទេ យប់ស្ងាត់ឈឹងយ៉ាងនេះ ។ ប្តីប្រពន្ធបណ្តើរគ្នាទៅយកភ្លើងឯផ្ទះ លុះចេញទៅផុត ម្តាយត្រូវខ្យល់ត្រជាក់ៗ ក៏ភ្ញាក់ដឹងខ្លួនថា កូនយកអាត្មាអញមកដុតទេតើ ទើបស្ទុះក្រោកឡើងចេញមក ឃើញសាកសពមួយ ក៏យកទៅរុំនឹងសំពត់ផ្តេកលើគ្រែរបស់ខ្លួនហើយរត់ចេញទៅចូលក្នុងគុហាមួយ ដែលជាកន្លែងពួកចោរធ្លាប់តែលួចទ្រព្យគេ យកមកលាក់ ។ ប្តីប្រពន្ធយកភ្លើងមកដុតសាកសពនោះ ស្មានថាម្តាយរបស់ខ្លួន រួចត្រឡប់មកផ្ទះវិញ ។ លំដាប់នោះ ចោរដើរទៅយកបង្អើបទ្រព្យដែលខ្លួនលាក់ក្នុងគុហា ស្រាប់តែឃើញយាយចាស់ នឹកស្មានថា យក្ខិនីឬខ្មោចបិសាច មកហួងហែងទ្រព្យរបស់ខ្លួន ក៏ត្រឡប់ទៅហៅពេទ្យអ្នកចេះចាប់ខ្មោចមក ។ លុះពេទ្យមកដល់តាំងប្រសិទ្ធមន្ត-វិជ្ជាដើរចូលទៅ ។ យាយចាស់និយាយថា ខ្ញុំមិនមែនជាយក្ខិនី ឬជាខ្មោចបិសាចអ្វីទេ ។ — ចុះធ្វើដូចម្តេចឲ្យយើងជឿផង ។ — អ្នកឯង-

លៀនអណ្តាតដាក់លើអណ្តាតខ្ញុំមក មុខជានឹងស្គាល់ហើយ ។ ពេទ្យលៀនអណ្តាតចេញមក, យាយចាស់ខាំជាប់ ដាច់អណ្តាតធ្លាក់មក; ពេទ្យស្រែកថា យ៉ៃ យក្កិនី; ចោរហើយនឹងពេទ្យក៏រត់ទៅផ្ទះវិញអស់ ។ លុះព្រឹកឡើង យាយចាស់ក្រោកយកសំពត់សាច់ល្អិតមកស្លៀក រួចទូលបង្វេចទ្រព្យមកផ្ទះរបស់ខ្លួន ។ កូនប្រសាស្រីឃើញដូច្នោះក៏សួរថា បពិត្រអ្នកម្តាយ អ្នកបានទ្រព្យទាំងនេះមកអំពីណា ។ ម្តាយក្មេកប្រាប់ថា ធម្មតាមនុស្សដែលគេយកទៅដុតក្នុងព្រៃស្មសាន តែងតែបានទ្រព្យយ៉ាងហ្នឹង ។ នាងនោះ ហេតុតែចង់បានទ្រព្យក៏ទៅប្រាប់ប្តីឲ្យយកខ្លួនទៅដុតក្នុងព្រៃស្មសាន ។ ប្តីយកប្រពន្ធទៅដុតមែន ហើយឈរថ្កោលមើលផ្លូវប្រពន្ធ ដល់មិនឃើញសោះ ទើបឆាកទៅសួរម្តាយថា បពិត្រអ្នកម្តាយ ថ្ងើរណោះហើយ ហេតុអ្វីក៏មិនឃើញប្រពន្ធខ្ញុំទូលទ្រព្យមកផ្ទះ ។ ម្តាយស្តីបន្ទោសថា "អាចង្រៃ អាឯងជាបុរសលាមក ធម្មតាមនុស្សដែលស្លាប់ហើយមិនដែលរស់មកវិញទេ កុំល្ងង់ពេក" រួចពោលគាថាមួយថា:

អាត្មាអញមានសេចក្តីត្រេកអរ បាននាំមកនូវស្រីដែល
ព្រោះព្រៃដោយខ្ញុំមចន្ទូរ៍ ពាក់ពាតដោយផ្កាកម្រង ស្រីនោះ
ទៅជាបណ្តេញអាត្មាអញឲ្យចេញអំពីផ្ទះ ភ័យទៅជាកើត
មកអំពីរបស់ដែលជាទីពឹង ។

បពិត្រមហារាជ ស្តេចជាទីពឹងរបស់ប្រជារាស្ត្រ ដូចជាកូនប្រសាស្រីជាទីពឹងរបស់ម្តាយក្មេកដែរ សូមព្រះអង្គជ្រាបរឿងនេះចុះ ។ — នៃ

មាណព រឿងនេះកំបាំងណាស់ យើងមិនយល់ទេ ត្រូវតែចាប់ចោរមកឲ្យយើង ៗ មាណពនាំនិទានមួយមកទៀតថា

បពិត្រព្រះសម្មតិទេព កាលពីដើមក្នុងនគរនេះ មានបុរសម្នាក់គ្មានកូនសោះ ខំបន់ស្រន់បានកូនប្រុសម្នាក់ ស្រឡាញ់ថ្នាក់ថ្នម បីបមរក្សា រៀបចំឲ្យមានប្រពន្ធ លុះដល់ខ្លួនចាស់ធ្វើការងារមិនកើត កូនសំឡាញ់នោះបណ្ដេញចេញអំពីផ្ទះ ទៅជាមនុស្សគេលគោល ឥតទីពឹង ដើរសុំទានគេ ចិញ្ចឹមជីវិតបាន ដោយត្រដាបត្រដួសត្អូញត្អែរថា

អាត្មាអញរីករាយនឹងកូន ប្រាថ្នាសេចក្ដីចំរើនដល់កូន
កូននោះទៅជាបណ្ដេញអាត្មាអញឲ្យចេញអំពីផ្ទះ ភ័យទៅ
ជាកើតមកអំពីរបស់ដែលជាទីពឹងវិញ ៗ

បពិត្រមហារាជ កូនដែលធំឡើងត្រូវតែថែរក្សាបិតាដែលចាស់ជរាយ៉ាងណា ស្ដេចត្រូវតែថែរក្សាជនបទទាំងមូល យ៉ាងនោះដែរ សូមព្រះអង្គជ្រាបថា ជនឯណោះជាចោរ ដោយហេតុនេះចុះ ៗ ព្រះរាជាទ្រង់មិនយល់ហេតុនោះ ទ្រង់ចាប់ផ្ដាក់ថា អ្នកឯងជាចោរទេដឹង បានជាមិនរកចោរឲ្យយើង ចេះតែបណ្ដោះបណ្ដែវេះវាងយ៉ាងនេះ ៗ — បពិត្រព្រះនរិន្ទ្រ ព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំ ចាប់ចោរពិតប្រាកដមែនឬ ៗ — អើ ប្រាកដមែន ៗ — បើដូច្នោះឲ្យទូលព្រះបង្គំជាខ្ញុំប្រកាសក្នុងកណ្ដាលបរិស័ទសិនថា ឈ្មោះនេះមួយ ៗ ជាចោរ ឬ? ៗ — អើប្រកាសចុះ ៗ មាណពហៅពួកអ្នកជនបទនឹងអ្នកនិគមឲ្យមកប្រជុំគ្នាហើយប្រកាសថា

អ្នកទាំងឡាយចូរចាំស្ដាប់ពាក្យរបស់ខ្ញុំចុះ ឥឡូវនេះ ទឹកត្រូវក្ដីវិនេះវិញហើយ សេចក្ដីក្រេមក្សាន្តធ្លាប់តែបានមកអំពីស្ដេច ឥឡូវនេះ ក៏យត្រឡប់ជាកើតមកអំពីស្ដេចវិញ ស្ដេចទីឝបុរោហិតតែងបូន់ពួកប្រស្ដ្រ អ្នកពល់គ្នាគ្មានស្ដេច គ្រប់គ្រងទេ ត្រូវប្រឹងប្រយ័ត្នទ្រព្យសម្បត្តិរៀងពល់ខ្លួនទៅចុះ ។

គ្រានោះ ពួកមហាជនបានស្ដាប់ជាក់ច្បាស់ហើយ ក៏ក្រោកស្ទុះទៅស្រវាចាប់ជំបង ៤ ជ្រុងតែពល់ដៃ ហើយទៅវាយសំពងស្ដេចទីឝបុរោហិតទាល់តែទីវង្គតស្លាប់ក្នុងពជបុរី ហើយអភិសេកមាណពឲ្យសោយរាជ្យជាស្ដេចក្នុងពេលនោះឡើង ។

ឯស្ដេចទីឝបុរោហិត ដែលបានទទួលទោសយ៉ាងធ្ងន់ដល់អស់ជីវិតនោះ មកអំពីទោសអទិន្នាទាន ។ ការលួចលាក់នេះ កុំបាច់និយាយឡើយដល់ទៅលួចទ្រព្យសម្បត្តិអ្នកដទៃ ទើបមានទោសនោះ សូម្បីលួចលាក់ទ្រព្យសម្បត្តិរបស់ខ្លួន គង់មានទោសយ៉ាងធ្ងន់ដល់អស់ជីវិតដែរ ដូចយ៉ាងស្ដេចទីឝបុរោហិតនេះ ព្រោះតែលួចលាក់ទ្រព្យរបស់ខ្លួនបានជាពួកប្រស្ដ្រវាយស្លាប់ ។

ឯអគ្គមហេសីដែលក្លាយខ្លួនទៅកើតជាយក្ខិនី ហើយស្លាប់អនាថានោះ ព្រោះទោសនៃការប្រព្រឹត្តមិច្ឆាចារ ហើយពោលកុហកព្រះរាជា ។

ឯអ្នករបាំឈ្មោះបាដលីដែលលង់ទឹកស្លាប់ ព្រោះទោសនៃការផឹកស្រា ។

ឯកូនប្រសាស្រីដែលត្រូវប្តីដុតចោលក្នុងព្រៃស្មសាននោះ ព្រោះទោសនៃបាណាតិបាត (ដុតសត្វទាំងរស់) ក្នុងកាលមុន ។

ចំណែកខាងមាណព ដែលបានឡើងគង់លើបល្ល័ង្កក្រោមស្វេតច្ឆ័ត្រទទួលរាជសម្បត្តិព្រោះនោះ មកអំពីគុណសម្បត្តិគឺចំណេះដែលរេះពិតប្រាកដ ។

ចំណេះអ្វីមួយដែលគេរេះពិតប្រាកដហើយ អាចនឹងលើកស្ទួយមនុស្សជាន់ទាបឲ្យឡើងកាន់ទីខ្ពស់បាន អាចនាំឲ្យបានសេចក្តីចំរើនរុងរឿងគ្រប់យ៉ាងទៅបាន ។

ចំណេះណាមួយដែលរេះមិនពិតប្រាកដហើយ អាចនាំឲ្យថោកទាបសាបសូន្យមិនខានឡើយ ។

ចប់បទកុសលជាតក

ទ្រព្យសម្បត្តិបានដោយការរិបជាន់គេពុំប្រសើរ

សម្រាប់មនុស្សទាំងឡាយ ការនៅព្រៃប្រសើរ, ការដើរសូមទានគេប្រសើរ, ការធ្វើឈលរែកពុនចិញ្ចឹមជីវិតប្រសើរ, ការឈឺចាប់ប្រសើរ, ឯទ្រព្យសម្បត្តិដែលបានមកដោយធ្វើជាអធិការ (ធ្វើជាធំលើគេ សង្កត់គេ) មិនប្រសើរឡើយ ។

បញ្ញត្រ្គ័ះ

## បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅភេទបព្វជិតពី ព.ស. ២៤៨៦ គ.ស. ១៩៤៣

(តមក)

---

## មហាសុរសេនជាតក ទី ១៤

លោកអាចារ្យ មៀវ-ធន្ធ វត្តលង្កា

ប្រែពីបាលី

(តកម)

---

អាមាត្យក្រាបទៀបព្រះបាទានៃមហាសត្វ សោកខ្សឹកខ្សួលអួលឱក អាល័យព្រះពជាឥតឧបមា ក្បន់ព្រះលោហិតដាក់លើសិរសាហើយ ត្រឡប់ទៅឯនគរ យកសេចក្តីក្រាបបង្គំទូលនាងទេវី នឹងប្រាប់ដល់ពួកមហាជនទាំងអស់ ៗ ពួកអ្នកនគរមានអាមាត្យជាប្រធាន នឹងអស់ស្រីស្នំទាំងប៉ុន្មាន ទិមិត្តតែបានឮពាក្យនោះហើយ ក៏ទ្រាំមិនបាន នាំគ្នាស្រែកយ៉ាងខ្លាំង ហើយចេញពាកនគរចូលទៅឧទ្យាន ក្បន់ព្រះលោហិតនៃមហាសត្វ ហើយលើកដៃឡើងទ្រហោយំទាល់តែសន្ធប់បាត់ស្មារតី ៗ ឯនាងទេវីព្រះនាមវិជ្ជុលតា ទ្រង់ត្រកងមហាសត្វ យកកួនសក់ជូតព្រះលោហិតយំនទៀលទៅមក ហាក់ដូចជាឆ្កួតលីលាសន្ធប់បាត់ស្មារតី ៗ កាលនោះជនទាំងឡាយ យកទឹកត្រជាក់ទៅស្រប់ព្រះភក្ត្រ ព្រះនាងបានភ្ញាក់ដកដង្ហើមរួច យកព្រះហស្តទាំង ២ គក់ព្រះឧរា ទ្រង់

ព្រះកន្សែងកប់រៀបថា "ឱ! ព្រះស្វាមីម្ចាស់ថ្លៃប្អូនអើយ, ខ្ញុំជាស្រីកំព្រាហើយ តាំងពីថ្ងៃនេះទៅ, ខ្ញុំម្ចាស់ជាស្រីមេម៉ាយ សមនឹងមានតែសេចក្ដីទុក្ខក្ដៅក្រហាយជាទម្ងន់", នាងកប់រៀបសព្វគ្រប់ហើយ នៅតែអត់សង្កត់មិនបាន ក៏ប្រះប្រាណសោយសោកសូរស្រូបស្រពាប់ស្រពោនក្រៀមក្រំហាក់នឹងស្លុតព្រះហឫទ័យ ៗ

តស្មិំ ខណេ ក្សណនោះសម្ដេចសក្កទេវរាជ ទ្រង់គ្រឿងអលង្ការដ៏រុងរឿងថ្កើងបវរ មកក្នុងដ៏អាកាស ហាក់ព្រះសុរិយារុងរឿងរះត្រចះចាំងរស្មី បង្ហាញព្រះអង្គឲ្យប្រជុំជនប្រុសស្រីបានឃើញហើយ ត្រាស់ហៅនាងទេវីថា ម្នាលនាងទេវី នាងកុំទ្រង់ព្រះកន្សែងសោយសោកឡើយ យើងនឹងឲ្យជីវិតដល់ស្វាមីរបស់នាងឥឡូវនេះឯង ៗ ហេតុតែអានុភាពនៃព្រះឥន្ទ្រ និងតេជះគុណបុណ្យព្រះមហាសត្វ ព្រះអង្គក៏កើតមានព្រះសិរសាឡើងមួយរំពេចក្នុងថ្ងៃនោះឯង ៗ ពួកមនុស្សម្នាមហាជនបានឃើញហេតុអស្ចារ្យដូច្នោះ ក៏នាំគ្នាថ្វាយសព្ទសាធុការលើកទង់ជ័យទាំងពាន់ថ្វាយបូជាព្រះមហាសត្វ ៗ ព្រះទេវីបានយល់ស្វាមីនាងជាឡើងដូច្នោះ ក៏ព្រឺព្រួចសោមនស្សលាន់ព្រះឱស្ឋថា យើងត្រូវតែធ្វើទានៗ ៗ កាលនោះ សក្កទេវរាជស្ថិតក្នុងដ៏អាកាសត្រាស់ថ្វាយព្រះពរសព្ទសាធុការថា "សាធុ! អ្នកសប្បុរសអើយ, អ្នកមាំងហើយជាទីពឹងនៃសត្វលោក, អ្នកបំពេញមហាបរិច្ចាគទាំង ៥ គឺ បរិច្ចាគសរីរាវយវៈ ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគជីវិត ១ បរិច្ចាគកូន ១ បរិច្ចាគប្រពន្ធ ១ យ៉ាងនេះហើយគង់នឹងបានជាព្រះពុទ្ធប្រាកដណាស់ពុំខាន" ព្រះឥន្ទ្រ

ត្រាស់យ៉ាងនេះស្រេចហើយក៏បាត់ពីកន្លែងនោះទៅ ។ តាំងពីថ្ងៃនោះមក ព្រះមហាសុរសេនតែងទ្រង់ធ្វើបុណ្យ មានឲ្យទានជាដើមរៀងរាល់វេលា លុះអស់ព្រះជន្មាយុកាលណា ស្តេចទៅឧប្បត្តិក្នុងពិភពតុសិត ។ ព្រោះហេតុនោះសម្តេចព្រះដ៏មានជោគទ្រង់ត្រាស់ថា:

បត្តំ ទត្វាន យេ ធីរា មហាពលបរក្កមា
អធិរា ឥទ្ធិសម្បន្នា មហាតេជា ជនប្បិយា
អនន្តបរិវារា តេ សព្វភោគេហិ មណ្ឌិតា
សត្តរតនសម្បន្នា ចក្កវត្តិ មហិទ្ធិកា ។ល។

ជនទាំងឡាយឯណា ជាអ្នកប្រាជ្ញ បានឲ្យបាត្រជាទាន, ជនទាំងឡាយនោះ ជាអ្នកមានកំលាំងនិងសេចក្តីព្យាយាមច្រើន ឥតមានពៀរវេរា បរិបូណ៌ដោយឫទ្ធិ មានតេជះច្រើន ជាទីស្រឡាញ់នៃជន មានបរិវារកប់មិនអស់ ប្រដាប់ដោយភោគ-សម្ប័ទគ្រប់យ៉ាង បានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានមហិទ្ធិឫទ្ធិបរិបូណ៌ ដោយសម្បត្តិជាកាមាវចររូបាវចរនិងអរូបាវចរ សោយសេចក្តីសុខជាលោកិយ, បើកើតក្នុងពុទ្ធុប្បាទ នឹងបានជាអ្នកប្រាជ្ញណែនាំបង្ហាញប្រយោជន៍ដល់សត្វក្នុងលោកទាំងមូល ជាម្ចាស់សព្វសត្វទាំងឡាយ, លុះចំណេរទៅឯក្នែក នឹងបានត្រាស់ជាព្រះពុទ្ធ ។

ជនទាំងឡាយឯណា បានឲ្យសង្ឃាដី, ជនទាំងឡាយនោះ

ជាអ្នកញាំញីមារសេនា ទុកជាប្រទះនឹងគូវវន្ទះខ្លាំងយ៉ាងណា ក៏មិនរំជួយរោមឡើយ មិនមានភ័យព្រឺស្បែកព្រឺរោមឡើយ, បានសោយសេចក្ដីសុខជាកាមភូមិ លុះចំណោរទៅឯមុខ នឹងបានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យចីវរជាទាន នឹងឈ្នះសង្គ្រាម បានជាឥស្សរកំពូលនៃជនទាំងអស់ លុះដល់កាលខាងក្រោយ នឹងបានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យស្បង់ជាទាន នឹងបានចៀរធ្លាសបេះវិន័យ ឈ្នះមារគ្រប់ប្រការជានិច្ច, លុះចំណោរទៅឯមុខ នឹងបានត្រាស់ជាព្រះពុទ្ធ ។

អ្នកឲ្យវត្តពន្ធជាទាន រមែងបានជាអ្នកស្អាត បរិសុទ្ធក្នុងកពទាំងឡាយជាធំក្នុងទីសព្វកន្លែង, លុះពេលខាងក្រោយ នឹងបានត្រាស់ជាព្រះពុទ្ធ ។

អ្នកដែលបរិសុទ្ធផុតពៀរវេរា បរិបូណ៌ដោយលក្ខណ៍ មានអាយុវែង មានសេចក្ដីសុខ ទាំងនេះជាផលនៃកាបិតគោរ ។

ជនទាំងឡាយឯណា កើតក្នុងកាលគួរ មានប្រាជ្ញាមុះមុត ចេះដឹងអាចសេចក្ដីសព្វគ្រប់ អង់អាច មានជ័យជំនះឈ្នះពួកទាំងពួង, ជនទាំងឡាយនោះលុះដល់ពេលខាងក្រោយ នឹងបានត្រាស់ជាព្រះពុទ្ធ ។

ជនទាំងឡាយឯណា ឲ្យអញ្ជុលជាទានដោយសទ្ធា ជនទាំងឡាយនោះនឹងមានអាយុវែង មានប្រាជ្ញាថ្លាស្អាត ជាពហុស្សូត ទ្រទ្រង់ធម៌ មានរូបល្អប្រាកដក្នុងលោក ។

ជនទាំងឡាយឯណា ឲ្យសំពត់ដម្រង់ទឹកដល់ភិក្ខុ ជនទាំងឡាយនោះលុះកើតក្នុងជាតិទាំងពួង រមែងចៀវថ្លាស ប្រាសចាកពៀរវេរា ត្រេកត្រអាលក្នុងឋានសួគ៌ មានរូបល្អ មានសម្បុរល្អ មានអាយុវែង មានឥន្ទ្រិយមិនលំបាក ។

ជនទាំងឡាយឯណា បានឲ្យឆត្រជាទានក្នុងពេលក្ដៅ ទោះឆត្រមាសក្ដី ឆត្រស្លាបក្អែកក្ដី ឆត្រសំពត់ក្ដី ឆត្រកែវក្ដី, ជនទាំងឡាយនោះរមែងបាននូវពួកបក្ខជ័ប្រសើរជានិច្ច ។ អ្នកឲ្យឆត្រជាទានក្នុងពេលក្ដៅនោះ រមែងបានគ្រឿងកកុធភណ្ឌ ៥ យ៉ាងគឺៈ ស្វេតច្ឆត្រ ១ ចាមរ ១ មុដ ១ ព្រះខាន់ ១ សុពណ៌បាទុក ១ ។

អ្នកមានសទ្ធាបរិសុទ្ធ បានប្រគេនរបស់ប្រកបដោយអង្គ ៨ ជាទេយ្យប្រសើរដល់ភិក្ខុទាំងឡាយ គឺត្រៃចីវរ ១ បាត្រ ១ កាំបិតកោរ ១ អញ្ជុល ១ វត្តពន្ធ ១ ដម្រង់ទឹក ១ អ្នកនោះនឹងមានបរិភោគមិនអស់ មានសក្ដិយសខ្ពស់អនេក ។

អ្នកឲ្យកម្រាលស្បែកជាទាន នឹងបានជាស្ដេចចក្រពត្តិ មានឫទ្ធិច្រើន មនុស្សក្នុងលោកទាំងអស់តែងស្រឡាញ់ចូលចិត្ត រមែងវៀរចាកភពមានរូបកពជាដើម ។

អ្នកឲ្យចីវរជាទាន នឹងបានសម្បត្តិច្រើន មានបុត្តច្រើន បរិបូណ៌ដោយកំលាំងច្រើន, លុះចំណេរទៅឯក្នែក នឹងបានដល់នូវព្រះនិព្វានជាឋានរលត់ទុក្ខ ។

នរៈនារី ដែលបានឲ្យគ្រឿងបរិក្ខារគ្រប់ប្រដាប់ នឹងបាន សម្បត្តិទិព្វ យសទិព្វ ខ្ញុំប្រុសខ្ញុំស្រីរាប់មិនបាន សោយសេចក្តីសុខក្នុងកាមលោក ដល់នូវសេចក្តីសុខក្នុងរូបលោក អរូបលោក, លុះចំណេរទៅឯក្នែក នឹងបានដល់នូវព្រះនិព្វាន ។

ភិក្ខុដែលប្រាថ្នាលោកុត្តរធម៌ ៩ យ៉ាង គួរបំពេញបារមី-៣០ ប្រការ ឲ្យគ្រប់ទាំងអស់ ដោយយល់ឃើញថា ទានបារមីជាឫសគល់, ព្រោះពុទ្ធគ្រប់អង្គទ្រង់សរសើរជានិច្ច អ្នកដែលមានបារមីគ្រប់គ្រាន់ហើយ រមែងដល់នូវព្រះនិព្វានជាប្រាកដ ។ លុះដល់ព្រះអរិយមេត្តេយ្យ មកឧប្បត្តិក្នុងជម្ពូទ្វីប ជនដែលបានឲ្យទាននោះ នឹងបានជាឯហិភិក្ខុក្នុងសំណាក់ព្រះអង្គ ប្រដាប់ដោយបាត្រ នឹងចីវរ ជាពុទ្ធបុត្រ មានបញ្ញាច្រើន សម្រេចដូចសេចក្តីប្រាថ្នា; ទាំងនេះក៏ព្រោះឲ្យទានគ្រឿងអដ្ឋបរិក្ខារ រមែងបានសព្ទសាធុការពរអំពីទេវតាទាំងឡាយ ដោយអានុភាពនៃគ្រឿងបរិក្ខារ; ព្រោះហេតុនោះ បណ្ឌិតអ្នកមានប្រាជ្ញាច្រើន កាលបើបានជួប

ជាឲ្យមានគ្រឿងបរិក្ខារមានផលច្រើនយ៉ាងនេះហើយ គប្បីឲ្យមានក្នុងកាលដែលមានសាសនាព្រះសម្មាសម្ពុទ្ធ ។

ព្រះបរមគ្រូជាម្ចាស់ កាលទ្រង់សំដែងព្រះធម្មទេសនាចប់ស្រេចហើយ ក៏ទ្រង់ប្រជុំជាតកថា នាងវិជ្ជុលតាទេវី ពីកាលនោះ ឥឡូវនេះបានមកជាមាតានៃរាហុលកុមារ នាមនាងយសោធរា, ឯរាជឱរសឈ្មោះវរជោតិកុមារ បានមកជារាហុល, សុចិរាមាត្យបានជាអានន្ទពុទ្ធុបដ្ឋាក, ព្រះមហិន្ទ្រាធិរាជ បានជាភិក្ខុឈ្មោះអនុរុទ្ធ មានចក្ខុទិព្វដ៏ឧត្តម, ព្រះបាទមហាសុរសេនរាជ ដែលមានព្រះទ័យត្រេកអរចំពោះទាន គឺអង្គព្រះសម្មាសម្ពុទ្ធ ជាទីពឹងនៃសត្វលោក ។ អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ មហាសុរសេនរាជជាតក ទី ១៤ ។

# ផ្នែកអក្សរសាស្ត្រ

## រឿងសៅរ៍សោយ

(សិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រស្លឹករឹត

(តមក)

---

ទើបហោរគន់គូរ ដោយនូវគំនូរ ពុំយូរលង់ឡើយ បូកលេខសាយសព្វ គ្រាន់គ្រប់ចប់ហើយ ពុំអែអង់ឡើយ ក្រាបហើយទូលថា ។

"បពិត្រនរបតី វរ័តនក្សត្រ បមស្រីធាយា បើតាមដំកាយ ទំនាយទាយថា នឹងមានកស្តា នៅនាធាប់ហើយ ។ ឯព្រះកស្តា ទំនាយទាយថា នៅនាបង្កើយ ចូលមកនៅក្នុងទីក្រុងនេះហើយ គ្មានផ្លាះនៅឡើយ ពិតហើយជាខ្សត់ ។ សព្វថ្ងៃអត់ឃ្លាន ធ្វើសមស្ងួមទាន គ្មានបានកំណត់ ផែកដោយពនផ្សារ តាមការក្រខ្សត់ ក្រោយទើបប្រាកដកំណត់បេស្តា" ។

ស្តេចស្តាប់ហើយនៃ ទ្រង់តូចព្រះទ័យ ពេកក្រៃណាស់ណា ទើបទ្រង់រំពឹង ផញ្ជឹងគិតថា អះ! នេះម្តេចក៏ ទើបជាយ៉ាងហ្នឹង!' ។ នឹកឡើងរឹងព្រួយ មានកូនតែមួយ ជាត្រួយព្រលឹង ទំនៃថែទាំ ល្មុះធំបុណ្ណឹង ព្រោះនឹករំពឹង ពំនឹងរាសនា ។ នឹកថាដល់ធំ មានគូផ្គំ ស្ងួនសមសក្តា

ទីងបែងរំលែក ចាត់ចែករដ្ឋា ឲ្យគ្រងសីមា ជាពាក់កណ្ដាល ។ នេះម្ដេច
ដូច្នេះ អក់ព្ធអីម្ល៉េះ ពុំបេះស្រែកស្រាល បើទុកឲ្យទៅ តៈទៅយូរកាល
នាំខ្លាសអម្បាល ញាតិពង្សវង្សា ។ ជម្រែះច្នេះសោត ព្រះអគ្គទ្រង់
ក្រោធ ប្រឡោតណាស់ណា ទ្រង់បញ្ជាចេញ ឲ្យដេញជីតា ចាកពី
សីមា រដ្ឋាកដឋាន ។ រីឯមហេសី សុទ្ធវតី ប្រិមប្រិយកល្យាណ
ជ្រាបថាស្ដេចក្រោធ ពិរោធពុំក្សាន្ត នាងទប់ពុំបាន ប្រះប្រាណ
សោកា ។ ទ្រង់ព្រះកន្សែង សោកយំចំបែង ថ្ងាថ្ងូងទ្ងូញថា "ឱកូន
មាសស្ងួន ខ្ញុំមខ្ញូនមាតា ហេតុកម្មាសនា ជីតាឯងហើយ ។ នេះគឺ
អំពើ ដែលនាងសាងធ្វើ ទើតើជាត្រើយ តាមស្នងសងផល អំពល់
ពុំស្បើយ ពុំឃ្លាតបាត់ឡើយ ទើបព្រាត់បុរី ។ ឱ! មាសស្នេហា
ព្រះវរបិតា ពុំត្រាប្រណី ពីដើមព្រះអគ្គ ស្ដេចទ្រង់ប៉ែតី ឥឡូវចក្រី
ឥតបីមេត្តា ។ ស្ដេចពុំអាណិត ធ្វើតាមព្រាហ្មណ៍ព្រិទ្ធ ជំនិតហោរា
ភបេះតែគាយ ទំនាយមុសា ស្ដេចពុំចិន្ដា សង្កាតិបឡើយ" ។ នាង
សោយសោកា អួលអន់ឧរា ទុក្ខាឥតស្បើយ ញាំអង្គចំប្រប់ សន្ធប់ជា
ត្រើយ លុះយូរតិចហើយ ទើបស្បើយឡើងវិញ ។ កាលបើស្រាក
ស្រាន្ត នាងយាងទៅប្ដាន ទោះឋានស្វាមី អង្វរព្រះអគ្គ ឲ្យទ្រង់
ប្រណី អាណិតបុត្រី ស្រស់ស្រីកល្យាណ ។ "បពិត្រវរវង្ស
សូមទានព្រះអគ្គ ស្ដេចទ្រង់ប្រោសប្រាណ ខ្ញុំទីងព្រះបង គ្រប់គ្រង
រដ្ឋឋាន មានកូនកល្យាណ ១ ប្រាណទេនៃ ។ ពុំគួរចក្រា ស្ដេច
ជឿហោរា ឫស្សាចង្រៃ ក្រោយបណ្ដេញកូន ខ្ញុំមខ្ញូនហឫទ័យ ចេញ

បាកវៀនជ័យ ឥតបីអាណិត ។ ចំនាយនេះណា ខ្ញុំម្ចាស់ឃើញថា ជាការពុំពិត បើមែនដូច្នោះ ក៏ព្រោះកម្មពិត ដែលពីអតីត(១) ខ្លួនគិត ខាងបាប ។ មួយទៀតជាតិស្រី ទោះមានស្វាមី ជាប្តីថៅកទាប ក៏ស្រេចតែកម្ម ប្រចាំអត្តភាព បានខ្ពស់ឬទាប តាមភាពវាសនា ។ បពិត្រវររង្ស ច្នេះសូមព្រះអង្គ ស្តេចទ្រង់មេត្តា កុំបណ្តេញកូន ខ្ញុំមខ្លួនធីតា ចេញផុតរជ្ជា ឡើយណាចក្រី ។ សូមទានព្រះចៅ ឲ្យសាងលំនៅ នាក្រៅបុរី ហើយឲ្យវាទៅ ដេកនៅនោះខ្ញុំ ទោះម្តេចៗ ក្តី ពសីផងវា ” ។

ព្រះបាទចក្រី ស្តាប់ស័ព្ទមហេសី មានក្តីមេត្តា ទើបគ្រាន់តែ ត្រាស់ ដេញព្រះធីតា ចេញពីសីមា ទៅនៅក្រៅវាំង ។ មហេសី ស្តាប់ច្បាស់ ក្រាបលាហ័ស រលះរលាំង ទៅរកកូនស្រី ក្សត្រី កាន់កាំង ឱបកូនហើយតាំង សោកាថ្ងូរថ្ងង ។

## បទព្រហ្មគីត (២)

កាលណោះព្រះមាតា សោយសោកាមហាចំបែង
នាងទ្រួញទំនួញថ្ងូង សោកកណ្តងវែងប្រមាណ
“ ឱ ! កូនស្ងួនដីវ៉ា ឥតនរណាជាពីរប្រាណ
ត្រាប់ចរក្នុងស្ថាន ព្រាត់ពីឋានដ៏ក្សាន្តទៅ ។

១ អានថា អះទិត ។ ២ បទនេះ មួយឃ្លាមាន ១១ ពាក្យ, ៤ ឃ្លាត្រូវដាក់ចុចសញ្ញា ១ ។ បទព្រហ្មគីតនេះ ត្រូវគ្នានឹងបទគីតនូវធីរធន្ន ឬ បទយានីខាងបាលី ដូច យោសន្និសិន្នោ ឬ យានីធភូតានិ ។ ដូច្នេះ តាមត្រូវ ក្នុងឃ្លាមួយ ៗ មិនគួរកាត់ជា ២ កំណាត់ ដូចដែលធ្លាប់ឃើញមកនោះទេ ។

ឱ! បុត្រវិសុទ្ធសួន    មាសខ្ញុំខ្ទួនទួនដោមឆ្ងៅ
ព្រាត់ឆ្ងាយពីម្តាយទៅ    ឲ្យម្តាយនៅសៅឯកា
កាលកូនសួននៅឡើយ    ម្តាយបានស្បើយល្ហើយឧរា
ឥឡូវព្រះបូរណា    ពុំមេត្តាត្រាប្រណី ។
មិនសមព្រះចមពង្ស    ស្តេចពុំទ្រង់ប្រោសបុត្រី
អាក្រក់ល្អម្តេចក្តី    កម្មកូនស្រីស្រេចហើយណា
ហេតុម្តេចស្តេចភ្លេចគិត    ពុំអាណិតចិត្តជីតា
ទោះអាប់យ៉ាប់ម្តេចម្តា    ពុំគួរណាដាច់ព្រះទ័យ ។
ឱ! កូនៗមាសម៉ុម    នាងធ្លាប់ផ្តុំៗសព្វថ្ងៃ
លើគ្រែៗមាសម៉័យ    ឥឡូវថ្ងៃៗព្រាត់ឆ្ងាយ
ទៅនៅក្រៅសីមា    តែឯកាណាមាសម្តាយ
គេងលើទីទាំងរ្យាយ    ដែលគួរណាយអនាថា ។
នាងធ្លាប់តែចាប់សោយ    ទូរព្រះស្ងោយឆ្ងាញ់ពីសា
កងបានសុវណ្ណា    ដំថ្ងៃថ្លាជាប្រក្រតី
តទៅត្រូវភោក្តា    តែផលាជាចំណី
កល់ពេលកល់ក្រើ    ពុំគួរអ៊ីស្រីរងកម្ម ។
ធ្លាប់គង់ក្នុងប្រាង្គប្រា-    សាទស្អាតថ្កុំជាប្រចាំ
គំនាល់គាល់ឆ្វេងស្តាំ    ចាំបំរើជាធម្មតា
ពេលនេះស្រស់ពាលពៅ    ត្រូវទៅនៅក្នុងគេហា
កណ្តាងងុងឯកា    គ្មាននរណាជាពីរត្រាណ ។

នរណាទឹងអាណិត　　មកជាមិត្តស្និទ្ធជិតឋាន
នរណាទឹងស្មោះស្មាន　　នាំកល្យាណសោយសោកជន
កូនអើយពីបុព្វ　　ប្រហែលមេសាងកម្មធ្ងន់
ទើបទៅត្រូវមកជន់　　ទុក្ខទូរន់ធ្ងន់ឥតបី ។
មុនកូនទៅផ្ចាប់ចរ　　ដោយព្រះមាសណាស្រី
គេទៅពៅពីសី　　ត្រូវឃ្លាតខ្ចីដោយបាទា
នាងឆ្ងាយពីម្តាយទៅ　　ឲ្យម្តាយនៅសៅកំព្រា
រងទុក្ខរងវេទនា　　ស្លាប់ទៅជាតិកប្ប ” ។
　កាលដែលព្រះជាយា　　សោកតពណ៌នាជាសេចក្តី
ជីតាថ្វាពីសី　　នាងឥតបីទឹងទប់បាន
ទឹកនេត្រហូរហៀរធ្លាក់　　ស្រោចព្រះកក្រអកកល្យាណ
នាងសោកអាមោកថ្កាន　　ទូញប្រែះប្រាណពុំមានស្បើយ ។
នូបហ្វាទព្រះមាតា　　ទូញទូលថាព្រះមេអើយ
នេះគឺកម្មកូនហើយ　　ពុំបាត់ឡើយតាមមកស្នង
ទើបកូនត្រូវព្រាត់ប្រាស　　ឃ្លាតនិរាសពេលនេះម្តង
ចាកទៅដោយសៅហ្មង　　ខុសបំណងផងមាតា ។
ព្រះម៉ែចំថែថួន　　ឲ្យកូនសួនបានសុខា
តាំងពីទារកា　　លុះដល់គ្រាធំប៉ុណ្ណឹង
សូមទ្រង់កុំសោកា　　តាំងចិត្តាក្សាំងប៉ឹង
នឹកជាចិញ្ចឹមហ្នឹង　　ដោយរំពឹងយកតែបុណ្យ ។

ទោះបីខ្ញុំម្ចាស់ បានក្រឡាស់មកតបគុណ
ឬកំខកស្កកស្កុន សូមព្រះគុណប្រោសផងក៉
សូមទ្រង់កុំទុក្ខឡើយ កូនលាហើយណា ម៉ែណា៎
ទោះសុខទុក្ខម្តេចម្តា តាមយថាកម្មបុព្វេ” ។
ត្រាស់ចប់ផ្ទិប់ក្រ្តា លើបាទានៃព្រះមេ
ពេលនោះក្សត្រទាំងទ្វេ មិនអត់ទេតាំងកន្សែង
នាងនាថនឹងមាតា សោយសោកាមហាកណ្តែង
យោបំយំចំបែង សោកថាថ្ងៃវែងប្រមាណ ។
លុះលន់ទន់សន្ធប់ ក្រាបស្ងៀមស្ងប់សព្វ ៗ ប្រាណ
យូរសល់ទើបកល្យាណ ទាំង ២ ប្រាណបានស្មារតី
ពេលនោះព្រះមាតា មានបញ្ញាសវនីយ៍
ត្រាស់ប្រើក្រុមវល្លកី(១) ឲ្យឃ្លាតខ្លីសាងដំណាក់ ។
មួយខ្នងនៅក្រៅក្រុង ទុកបំរុងអនន្តល័ក្ខណ៍
គ្រាន់នឹងនៅពឹងពាក់ បានសំណាក់ស្នាក់អាស្រ័យ
ហើយចាត់អស់បរិវារ នឹងបរិក្ខារជាច្រើនក្រៃ
មាសពេជ្រកែវចរណៃ អាវសារស្បៃឲ្យធីតា ។ (មានត)

---

១ វល្លកី ប្រែថា ជាង, ជាងឈើ ។

## កណ្ឌទី ២១

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាំងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯទីប្រឹក្សាទាំងពួងក៏និយាយនឹងឡៀវពៀវថា យីអេងពោលទ្រគោះមើលងាយលោកខ្លាំងណាស់ ហេតុម្តេចបានជាលោកមិនសម្លាប់ចេញ? ៗ ឡៀវពៀវតបថាយើងដឹងដំណឹងថា យីអេងនេះមានដំរេះប្រាជ្ញា តែជាមនុស្សគ្មានអធ្យាស្រ័យសោះ, កាលនៅក្នុងស្រុកហ៊ូតោនោះ ក៏បានពោលទ្រគោះមើលងាយចូចូជាច្រើនលើក ចូចូសម្រាហ៍ទ្រាំអត់សង្កត់ចិត្តមិនបានសម្លាប់យីអេង ព្រោះតែអេងខ្លាចមនុស្សទាំងពួង នឹងគរហានិន្ទាប្រការ ១ ទៀតបើមានអ្នកឯណាចូលមកយកអាសាធ្វើការជាមួយផង ក៏រមែងស្ញើរចិត្តដ្បិតឃើញសម្លាប់មនុស្សល្អ បានជាចូចូក្លែងប្រើយីអេងមកបញ្ចុះបញ្ចូលយើង ប្រាថ្នាដើម្បីនឹងខ្ចីដៃយើងឲ្យសម្លាប់យីអេងចេញ នឹង

ឲ្យសេចក្ដីអាក្រក់នោះធ្លាក់មកលើយើង ។ ត្រូវក្រុងឲ្យយីអេងទៅបញ្ចុះបញ្ចូលហានចិ ព្រោះហានចិចិត្តស្រាលរហ័សគ្មានអ្វីទប់ បើយីអេងទៅនិយាយទៅគោះពោះពោកឲ្យហានចិប្រការម្ដេច ហានចិក៏នឹងសម្លាប់យីអេងមិនខាន បើដំណឹងនេះដឹងទៅដល់ចូចូវេលាណា ឃើញថាចូចូនឹងគោតខ្លាចគំនិតយើងថា យើងដឹងដល់គំនិតចូចូ ។

ទីប្រឹក្សាទាំងពួងក៏សរសើរឡៅពៀវថា មានប្រាជ្ញាឈ្លាសវៃស្រ-ដីថា លោកគិតនេះត្រូវល្អណាស់ ។ ខណៈនោះ មានបំរើអ៊ួនសៀវគាន់សំបុត្រមកឲ្យឡៅពៀវ សេចក្ដីថា "ឲ្យឡៅពៀវជួយគិតការទំនុកបំរុងផែនដី" ។ ឡៅពៀវក៏ប្រឹក្សានឹងសេនាធាហានទាំងពួងថា ចូចូនឹងអ៊ួនសៀវជាសត្រូវនឹងគ្នា ឥឡូវចូចូនឹងអ៊ួនសៀវឲ្យមកបញ្ចុះបញ្ចូលយើងទាំងសងខាង តើអ្នកទាំងពួងនឹងយល់ឃើញប្រការម្ដេច? ។

ហាន់សុងឆ្លើយថា ចូចូនឹងអ៊ួនសៀវគ្រានេះជាទោសទាស់ធ្វើសង្គ្រាមនឹងគ្នា បើលោកមិនចូលទៅខាងណា នឹងគិតឲ្យជាប្រយោជន៍ចូរមើលកលការ បើឃើញខាងណាភ្លាត់ចំណាប់ត្រូវលោកលើកកងទ័ពទៅព្រួតវាយខាងណោះយកស្រុកឲ្យបាន តែខ្ញុំបាទខ្លាចក្រែងនៅ១ ថាចូចូនោះមានសតិបញ្ញាច្រើនណាស់ ឈ្លាសយល់ទាំងក្បួនពិជ័យសង្គ្រាមស្ទាញស្ទាត់ជាងអ៊ួនសៀវ ហើយចេះចិញ្ចឹមរក្សាមនុស្សល្អមានលក្ខណៈតាមវិជ្ជានឹងថ្វីដៃមនុស្សទាំងពួងក្នុងផែនដី ក៏ចុះចូលទៅនៅនឹងចូចូជាច្រើនមិនដាច់សោះ ខ្ញុំបាទយល់ឃើញថា ចូចូនោះ នឹងធ្វើការសឹកសង្គ្រាមគង់មានជ័យជំនះអ៊ួនសៀវមិនខាន បើចូចូបានស្រុកគីជីវហើយ

មុខជាលើកកងទ័ពទៅវាយយកស្រុកធំ ៗ ខាងទិសឯកើតរហូតដល់ស្រុកកាំងតាំង ពោះយ៉ាងណាក៏គង់ល់ទឹងប្អូនមិនបាន សូមឲ្យលោកស្ម័គ្ររាប់អានចូលទៅខាងប្អូនចុះ មុខជាប្អូននឹងទំនុកបំរុងលោកជាប្រក្រតីតទៅ ។

ឡៅពៀរឆ្លើយថា បើដូច្នោះចូរអ្នកចេញទៅស៊ើបសួរស្ដាប់ការណ៍ក្នុងក្រុងហ៊ូតោចុះ បើដឹងការណ៍យ៉ាងណាហើយ ចូរអ្នកវិលត្រឡប់មកប្រាប់យើង ៗ នឹងបានត្រិះរិះគិតការណ៍នេះតទៅទៀត ។ ហាន់ស៊ុងជំរាបថាដែលលោកនឹងប្រើឲ្យទៅយ៉ាងម្ដេច ខ្ញុំបាទមិនទទឹងនឹងប្រសាសន៍ទេ ខ្លាចតែព្រះចៅហៀនតេនឹងជប់លៀង ឲ្យខ្ញុំធ្វើនាហ្មឺនខាងក្នុង នឹងមិនបានត្រឡប់មកជាគៀនស្លាប់រស់ជាមួយនឹងលោក មុខជាលោកមានសេចក្ដីសង្ស័យនឹងខ្ញុំបាទ ។ ឡៅពៀរតបថា ដែលអ្នកនិយាយដូច្នេះគួរហើយ តែថាទោះបីយើងនឹងនៅឆ្ងាយពីគ្នាយ៉ាងណា ក៏ត្រូវឲ្យមានចិត្តស្រឡាញ់គ្នាយ៉ាងជិតស្និទ្ធដូចជីវិត ១, ដែលអ្នកនឹងទៅនោះ បើបានដឹងកិច្ចការអ្វី ៗ ខ្លួនមិនបានមក ក៏ត្រូវធ្វើសំដីដោយសំបុត្រលិខិតមកដល់យើងឲ្យដឹង ដើម្បីនឹងបានគិតការតទៅ ។

ហាន់ស៊ុងក៏លាឡៅពៀរចូលទៅស្រុកក្រុង លុះដល់ហើយក៏ចូលទៅគំនាប់ប្អូន ៗ ឃើញហាន់ស៊ុង ទៅដល់ក៏ទទួលដោយអំណរគួរសមណាស់ សាកសួរសុខទុក្ខយ៉ាងស្និទ្ធស្នាល ហើយតាំងឲ្យធ្វើជានាហ្មឺនខ្ញុំរាជការក្នុងព្រះចៅហៀនតេ ហើយឲ្យស្រុកឡេងឡេងឡើងស្ដាប់បង្គាប់ហាន់ស៊ុង ។ ស៊ុនហុកទើបចូលមកខ្សឹបសួរប្អូនថា ខ្ញុំបាទឃើញថា

ឡេវពៀវប្រើហាន់សុងឲ្យមកស៊ើបស្តាប់ការជាសម្ងាត់ ខ្ញុំហាន់សុងមិនទាន់មានគុណបំណាច់អ្វីនឹងលោកសោះ ហេតុះម្តេចបានជាលោកតាំងហាន់សុងឲ្យធ្វើនាហ្មឺនបានខែ ត្រឡេងឡេងឡើងស្តាប់បង្គាប់ ប្រការ១ យីអេងដែលទៅបញ្ចុះបញ្ចូលឡេវពៀវនោះ ក៏នៅមិនទាន់បានសេចក្តីអ្វីមកដល់លោក ៗ ក៏មិនបានសួរការណ៍នេះដល់ហាន់សុងសោះ ។

ចូឆូតបថា "យីអេងនោះអាក្រក់ជួជាតិប្រមាថមើលងាយយើងជាច្រើន យើងមានចិត្តខឹងក្តៅនៅជាប់ ប៉ុន្តែមិនសម្លាប់ចេញមនុស្សទាំងពួងនឹងគរហាទិន្នថា យើងមានពិសនាធ្វើធំក៏ហែងអ្នកតូច បានជាយើងប្រើឲ្យទៅបញ្ចុះបញ្ចូលឡេវពៀវ ប្រាថ្នានឹងខ្ចីដៃឡេវពៀវឲ្យសម្លាប់យីអេងចេញ ដែលនឹងសួរដំណឹងនោះ ក៏មិនជាការប្រយោជន៍អ្វី" ហើយចូឆូក៏បង្គាប់ហាន់សុងឲ្យវិលទៅស្រុកកេងជីវវិញ ឲ្យបញ្ចុះបញ្ចូលឡេវពៀវមកចូលធ្វើរាជការនឹងយើងឲ្យបាន ។

ហាន់សុងទទួលពាក្យចូឆូ ហើយក៏លាត្រឡប់ទៅស្រុកកេងជីវ លុះទៅដល់ហើយក៏អធិប្បាយរឿងដែលចូឆូនិយាយ នឹងតាំងខ្ញុំឲ្យធ្វើនាហ្មឺននោះឲ្យឡេវពៀវស្តាប់គ្រប់ប្រការ ហើយថា ចូឆូនោះមានចិត្តបវរទូលាយ ស្រឡាញ់ប់អានមនុស្សទាំងពួង គួរណាស់លោកនឹងចូលទៅធ្វើរាជការជាមួយផង សូមឲ្យលោកចាត់យកបុត្របស់លោកចូលទៅថ្វាយជាចំណាំព្រះចៅហៀនតេ នឹងបានធ្វើរាជការជានាហ្មឺនតទៅ ។ ឡេវពៀវបានឮដូច្នេះក៏ខឹងណាស់និយាយថា "ខ្ញុំមិនយកសេចក្តីអាថ៌កំបាំងរបស់យើងទៅប្រាប់ចូឆូហើយឬ? បានជាចូឆូតាំងឲ្យខ្ញុំធ្វើជានាហ្មឺន,

ដែលខ្លួនគិតធ្វើការយ៉ាងនេះ ក៏ឃើញថាខូចយសនឹងយើង" ហើយបង្គាប់ឲ្យចាប់ខ្លួនហាន់សុងទៅសម្លាប់ ។ ហាន់សុងឆ្លើយថា ខ្ញុំបាននឹងគិតប្រទូសរ៉ាយចំពោះលោកក៏ទេ នឹងបានលះបង់ចោលលោកក៏ទេ ហេតុម្ដេចលោកត្រឡប់លះបង់ចោលខ្ញុំបាទវិញ ។

គេងលៀងបានឮដូច្នោះ ក៏និយាយនឹងឡៅពៀវថា កាលលោកប្រើហាន់សុងឲ្យទៅនោះ ហាន់សុងក៏បាន ឆ្លើយដំរាបលោកទុកថា ដែលលោកឲ្យចូលទៅស្រុកក្រុង ក្រែងលោកនៅមានសេចក្ដីសង្ស័យ លោកក៏បានថាមិនមានសង្ស័យអ្វីទេ បានជាហាន់សុងទៅ ឥឡូវហាន់សុងត្រឡប់មកវិញ ជូនដំណឹងកិច្ចការឲ្យលោកជ្រាបតាមពិត, ដែលលោកមកប្រើឲ្យគេសម្លាប់ហាន់សុងចេញ មិនសួរសោះ ។ ឡៅពៀវយល់ថាខ្លួនគិតខុសក៏ព្រមលើកទោសហាន់សុង ។ ខណៈនោះទទួលបំរើសេះមកប្រាប់ឡៅពៀវថា យីអេងដែលទៅនិយាយបញ្ចុះបញ្ចូលហាងចចៅហ្វាយស្រុកកាំងហែនោះ ហាងចរៀបតុលៀងអាហារឲ្យយីអេងបរិភោគតាមទំនៀម លុះសេពសុរាស្រវឹងផងគ្នា ហាងចក៏សួរយីអេងថា ក្នុងក្រុងហ្វូតោនោះ អ្នកបានឃើញនាហ្មឺនណាមានសតិបញ្ញាជ្រៅឆ្ងាយខ្លះ យីអេងប្រាប់ថា ខុងយ៉ុងនឹងអៀវតើវ ២ នាក់នេះ សុទ្ធតែមានដំរេះចេះគិតគូរគ្រាន់បើ ក្រៅពីនេះមិនឃើញមាននរណាសោះ ហាងចថា ដំរេះខុងយ៉ុងនឹងអៀវតើវហើយនឹងដំរេះយើងនេះ អ្នកឯងឃើញជាយ៉ាងម្ដេចពីគ្នាខ្លះ? យីអេងថា ដំរេះអ្នកឯងនេះឧបមាដូចជាដុំថ្មនៅក្នុងខ្ទមទេពារក្ស ទោះនឹងមានគេមកសែនព្រេនថាប្រការម្ដេច ដុំថ្មនោះក៏មិន

ប៉េះឆ្លើយតទឹងអ្នកដែលបួងសួងនោះឡើយ ឧបមាដូចជាសំពះដុំឈើ ១ កំណាត់ ហងចបានព្យួរដូច្នោះក៏ខឹងខ្លាំងណាស់ ហូតក្រប៉ីចេញហើយ ក៏លើកឡើងកាប់យីអេង ៗ ដេរប្រទេចហងចតាលតែជាចំឡល់ស្លាប់ ។ ឡេវពៀវបានស្តាប់ដូច្នោះក៏មានចិត្តអាណិតយីអេងណាស់ ប្រើមនុស្សឲ្យទៅរៀបសក្ការសពកប់យីអេង ទុកនៅតំបន់អើងប៊ូជីវ ឯឡេវពៀវនោះក៏មិនបានគិតទឹងចូលទៅខាងចូឆូទេ ។

កាលចូឆូឮដំណឹងថាយីអេងស្លាប់ ក៏អស់សំណើចហើយនិយាយថា យីអេងនេះជាមនុស្សអាក្រក់ណាស់ មាត់របស់វាជាអាវុធសម្លាប់ខ្លួនវាទៅឯង ៗ ខណៈនោះចូឆូនៅចាំស្តាប់ដំណឹងឡេវពៀវ តែមិនបានដំណឹងប្រការម្តេចសោះ ទើបប្រមូលសេនាទាហានទាំងពួងទឹងលើកទ័ពទៅវាយយកស្រុកកងជីវ ។ ស៊ុនហុកក៏ហាមឃាត់ចូឆូថា អ៊ួនសៀវមានកំឡាំងច្រើនណាស់ទាំងឡេវពីក៏ប្រែគំនិតចិត្តចេញពីលោកទៅផង មុខជាចូលគំនិតគ្នាទឹងអ៊ួនសៀវ ត្រូវតែគិតបង្ក្រាបអ៊ួនសៀវទឹងឡេវពីឲ្យរៀបទាបចេញសិន សឹមលើកទ័ពទៅប្រាបប្រាមឡេវពៀវទឹងបានដោយងាយ ។ ចូឆូយល់ឃើញត្រូវ ក៏គិតថាទឹងលើកកងទ័ពទៅច្បាំងទឹងអ៊ួនសៀវ, ឡេវពី, តែសេចក្តីនេះចូឆូមិនទាន់ប្រឹក្សាទឹងអ្នកឯណា ក៏បង្អង់នៅស្ងៀម ។ លុះព្រះចៅហៀនតេស្តេចទៅគង់ក្នុងស្រុកហ៊ូតោបាន ៥ ព្រះវស្សាហើយ ខណៈនោះជាទេសកាលខែមាឃចូលឆ្នាំចិន ចូឆូទឹងនាហ៊ឺនមុខមន្ត្រីខ្ញុំរាជការទាំងឡាយ គាត់តែងជួបទៀនមានផ្កាឈើទឹងគ្រឿងប្រដាប់ចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេតាមទំនៀម ។

តាំងស៊ិនទឹងមន្ត្រីទាំងពួង ឃើញបូចធ្វើបុកពាមិនកោតខ្លាចមិនចង់ថ្វាយបង្គំព្រះចៅហៀនគេ នាហ្មឺនដែលមានចិត្តសុចរិតទៀងត្រង់នឹងផែនដីក៏នាំគ្នាទឹងក្ដៅទឹងបូចជាច្រើន លុះព្រះចៅហៀនគេស្ដេចយាងចូលហើយ បូចទឹងបណ្ដាខ្ញុំរាជការតូចធំក៏នាំគ្នាត្រឡប់ទៅផ្ទះ ។ ឯតាំង-ស៊ិននោះ តាំងពីក្រោយឡើងពីលើកទ័ពចេញទៅ ទាំងម៉ាថេងក៏លើកទ័ពចេញទៅក្រុងសេលៀងៈទៀត តាំងស៊ិនទឹងដូហ៊ុក, ដូទ្យាន់, តាំងអ៊ុច, ង៉ោហ្វូនលបគិតគ្នាកល់ៗថ្ងៃដើម្បីនឹងរំលាយបំផ្លាញបូច តែមិនសមតាមសេចក្ដីប្រាថ្នា ទាំងអស់គ្នាក៏មានបរិវិតក្កទុក្ខពោមនស្សមិនដេក មិនស៊ីឲ្យសប្បាយ, តាំងស៊ិននោះក៏បណ្ដាលជម្ងឺក្ដៅក្រហាយដេកឈឺក្នុងផ្ទះ ។

ព្រះចៅហៀនគេទ្រង់ជ្រាបថា តាំងស៊ិនមានជម្ងឺឈឺ ក៏ត្រាស់ប្រើកៀតប៊ុងជាពេទ្យហ្លួងឲ្យទៅព្យាបាលអាការរោគតាំងស៊ិន កៀតប៊ុងក៏ទៅព្យាបាលទាំងពេលយប់ពេលថ្ងៃ ឃើញតាំងស៊ិនដេកដកដង្ហើមធំរឿយៗ ក៏ដឹងថាមិនមែនជម្ងឺធម្មតាគឺរោគឈឺចិត្ត កៀតប៊ុងមិនអាចសួរសាកប្រការម្ដេច លុះព្រឹកឡើងថ្ងៃ ១ នោះ កៀតប៊ុងក៏និយាយនឹងតាំងស៊ិនថា ថ្ងៃនេះខ្ញុំបាទសូមលាលោកទៅ ស្អែកសឹមត្រឡប់មកវិញ ។ តាំងស៊ិនក៏និយាយឃាត់ថា ថ្ងៃនេះអ្នកកុំអាលទៅឡើយ នៅដេកនឹងយើងមួយយប់សិន តាំងស៊ិនក៏ឲ្យរៀបតុៈល្មៀងអាហារ ហើយអញ្ជើញកៀតប៊ុងមកផឹកស្រាជាមួយគ្នា ។ តាំងស៊ិនបរិភោគកាលណា ក៏គិតដល់សេចក្ដីដែលគិតទុកនោះឲ្យព្រួយរំខានពន់ប្រមាណណាស់ ធ្វើសញ្ញារតីទំរេតខ្លួនលក់លើកៅអីតាំងទៅ យល់សប្តិឃើញថា ‘ ដូហ៊ុក,

ដូឡាម់, តាំងអ៊ុប, ង៉ោហ៊ួន ៤ នាក់នេះ នាំគ្នាមករកតាំងស៊ុនឯផ្ទះហើយ ប្រាប់ថា ឥឡូវអួនសៀវនឹងឡេវពីលើកទាហាន ១០ ម៉ឺនចូលមកពីខាងទិសឯត្បូង ម៉ាថែងនឹងហាន់ស៊ុយលើកទាហាន ៧២ ម៉ឺនចូលមកពីទិសឯជើង នឹងមកវាយយកស្រុកហ៊ូគោ ឯចូចូកំលើកទាហានចេញទៅតទល់ខាងក្រៅកំពែងស្រុកទាំង ២ តំបន់ គង់ស្រុកនោះនៅតែចូចូនឹងកូនទាហានប្រមាណ ៩–១០ នាក់ តាំងស៊ុននឹងមន្ត្រី ៤ នាយក៏ពាក់ក្រិសជិះសេះកាន់អាវុធគប់ដៃ ហើយលើកទាហានទៅដល់មុខផ្ទះនោះ ឃើញចូចូកំពុងអង្គុយផឹកស្រា តាំងស៊ុនក៏បរសេះជម្រង់ចូលទៅយកគ្រប៉ីកាប់ក្បាលចូចូដាច់ធ្លាក់ពីលើស្មាស្លាប់ ហើយតាំងស៊ុនដេរចូចូថាអាក្បត់ ” ខណៈនោះតាំងស៊ុនក៏មានចិត្តត្រេកអរសប្បាយ ក្អាក់ជង់ខ្លួនហើយក៏នៅដេរចូចូមិនឈប់មាត់ ។

កៀតប៊ុងបានឃើញតាំងស៊ុនមម៉ៃដេរចូចូដូច្នោះ ក៏ដឹងថា តាំងស៊ុនមានចិត្តស្អប់ចូចូ ប្រែងនឹងបង្ខូសវាយចូចូ កៀតប៊ុងក៏ជជីកសួរតាំងស៊ុនថា លោកប្រែងនឹងធ្វើអន្តរាយមហាឧបាកជ្ឈ ! ខ្ញុំនឹងនាំយកសេចក្តីនេះទៅប្តឹងឲ្យមហាឧបាកជ្ឈជ្រាប ។ តាំងស៊ុនបានឮកៀតប៊ុងថាដូច្នោះ ក៏ភ័យស្លុតស្មារតីមិនឆ្លើយតបថាអ្វីសោះ ។ កៀតប៊ុងឃើញតាំងស៊ុនភ័យខ្លាចដូច្នោះក៏និយាយថា លោកកុំភ័យខ្លាច ខ្ញុំបាទថាដូច្នេះព្រោះចង់ពិសោធចិត្តលោកទេ សព្វថ្ងៃនេះខ្ញុំបាទគ្រាន់តែធ្វើពេទ្យ តែដួងចិត្តគិតនឹងតបស្នងគុណព្រះចៅហៀនតេជាដកប ដែលខ្ញុំបាទមកនៅព្យាបាលពេតលោកយូរថ្ងៃ ហើយមិនបានដឹងប្រាកដថា ពេតលោកនោះកើតអំពីអ្វី

ឃើញលោកបេះផ្លែដកឈើមធំរឿយៗ ខ្ញុំបាទក៏មិនអាចហានសួរ ឥឡូវខ្ញុំបាទបានឃើញលោកមមើដេរចូរ ក៏ត្រូវគ្នានឹងដកឈើមធំ ឯការដែលលោកគិតទុកប្រការម្តេចនោះ ចូរលោកកុំលាក់ឡើយ ប្រាប់ខ្ញុំបាទឲ្យត្រង់មកចុះ បើល្មមខ្ញុំបាទនឹងទទួលធ្វើបាន ខ្ញុំបាទក៏ទទួលយកអាសា ។

តាំងស៊ុនបានឮកៀតប៊ុននិយាយដូច្នោះក៏យំហើយថា យើងបាវម្តូវតែបិតអ្នកនឹងមិនដូចមាត់និយាយ ការដែលយើងគិតទុកនឹងខូចអសារទៅ ។ កៀតប៊ុនឆ្លើយថា "បើលោកសង្ស័យខ្ញុំបាទនឹងធ្វើឲ្យជាបន្ទាល់ច្បាស់" និយាយហើយកៀតប៊ុនក៏យកក្រចកាត់ម្រាមដៃ ឲ្យលោហិតហូរចេញមកដាក់លាយនឹងស្រាក្នុងពែង ហើយលើកឡើងស្បថសច្ចាថា "ខ្ញុំបាទមានចិត្តសុចរិតត្រង់នឹងផែនដី បើមានសេចក្តីវៀចវេរក្បត់បញ្ឆោតលោក ក៏សូមឲ្យដីវតខ្ញុំបាទអន្តរាយដោយអាវុធផ្សេងៗ ចុះ" លុះសច្ចាហើយកៀតប៊ុនក៏ផឹកអស់ទៅ ។ តាំងស៊ុនបានឃើញកៀតប៊ុនស្បថសច្ចាជាទីអស្ចារ្យដូច្នោះក៏អស់សង្ស័យ ទើបយកឡាយព្រះហស្តមកបង្ហាញឲ្យកៀតប៊ុនមើល ហើយថា "ដែលយើងរួមគំនិតគិតគ្នានឹងកបាត់ចូរចេញនោះ ៧ នាក់ទាំងខ្លួនយើង ឥឡូវឡៀតនឹងម៉ាបេងក៏ចេញពីស្រុកក្រុងអស់ទៅហើយ នៅតែយើងនឹងមន្ត្រីមានឈ្មោះ ៤ នាក់បានជាគិតការមិនដុះដាយ យើងក៏ទៅជាឈឺព្រោះហេតុនេះ ។ កៀតប៊ុនឃើញឡាយព្រះហស្តព្រះចៅហៀនតេ ហើយស្តាប់ពាក្យតាំងស៊ុននិយាយដូច្នោះ ក៏ឆ្លើយតបថា ការដែលឯងគិតធ្វើអន្តរាយចូរនោះ ទុកជាកិច្ចធុរៈលើខ្លួនខ្ញុំបាទចុះនឹងទទួលយកអាសា ។ (មានត)

ដំណើរតាមខ្យល់ក្នុងគារាគារ

# លោកផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

ខណៈនោះ អ៊ីស្មាអ៊ីលចូលទៅជិតនាងនារីឡៃឡា ហើយនិយាយប្រាប់ដោយសុន្ទរកថាប្រកបដោយមុទុចិត្តថា:

– "បើអូនឃ្លាន ចូរតារវត្ថុដែលពេញចិត្តពីលោកតានេះ ។ ផ្លែឈើក្នុងសួន សម្រាប់បំបាត់ការស្រេករបស់អូន, បន្ទុកក្នុងចំការ សម្រាប់បំបាត់ការឃ្លានរបស់អូន, វឿងព្រេងរបស់តាឡិប សម្រាប់ធ្វើឲ្យអូនរីកពាយបាត់អផ្សុក, នៃឡៃឡាមាសបង ! ចូរអូនគេងជាសុខ ចូរមានក្តីទុកចិត្តលើរូបបងជាសំឡាញ់ចុះ" ។

នាងឡៃឡាស្ទុះទៅចាប់ដៃអ៊ីស្មាអ៊ីលហើយថើបដោយកតញ្ញូ លុះនាងងើបមុខឡើង អ្នកកំឡោះឃើញដលនេត្ររលេងរលោងក្នុងកែវកែកភ្នែកតរបស់នាង ។

អ៊ីស្មាអ៊ីលខ្វល់ក្នុងចិត្តពេក ទើបសួរក្រោមថា:

– "អូនមានទុក្ខដូចម្តេច ?" ។

នាងឡៃឡាយំអណ្តឹតអណ្តក ហើយនិយាយប្រាប់ពីដំណើរបងស្រីដែលនៅតែម្នាក់ឯងក្នុងវាលខ្សាច់ ។

– "ឱព្រះគុណម្ចាស់ថ្លៃ ! ខ្ញុំសូមអង្វរលោក សូមលោកមេត្តាជួយស្រង់ជីវិតបងស្រីខ្ញុំផង !" ។

អ៊ីស្មាអ៊ីលប្រាប់ថា:

– 'បងសូមសន្យាថានឹងទៅរក ពេលស្អែកពីព្រលឹម ។ យប់នេះហួសហើយមើលអ្វីមិនឃើញទេ កណ្ដាលផ្លូវខ្សាច់ ។ តែបងនឹងចេញទៅរកមុនព្រះអរុណរះបញ្ចាំងរស្មីមកលើព្រះធរណី ។ ឱ ឡីឡាមាសព្រលឹងបង ! ចូរអូនស្ងៀមចុះ សូមព្រះអាឡស់ជួយរក្សាខ្លួនអូននឹងជនទាំងប៉ុន្មានដែលអូនគាប់ចិត្ត" ។

អ៊ីស្មាអ៊ីលឈប់បង្អង់នៅត្រង់នោះយូរបន្តិច ដោយគេចង់ដឹង តើតាឡិបលាក់នាងទុកត្រង់ណា ។

តាឡិបមានឡាំងសម្រាប់ដាក់ស្មៅសេះមួយនៅសល់ទំនេរ ។ ក្នុងឡាំងនោះគាត់ដាក់ជួយរបស់គាត់ ។ បើប្រសិនជាខ្វាចក្រែងចូលទៅក្នុង ហើយរហាប់គ្មានខ្យល់អាកាស ដែលនាំបណ្ដាលឲ្យដកដង្ហើមមិនស្រួល គង់នៅមានអានសេះ តែបសេះជាច្រើនដែលអាចដាក់បង្គរបំបាំងបានដោយត្រឹមត្រូវ ។

កាលណាកិច្ចការរៀបចំស្រេចអស់ហើយ កាលណាអ៊ីស្មាអ៊ីលដឹងប្រាកដថាឡីឡាមិនមានអន្តរាយហើយ គេឲ្យពរគ្រឹសុវត្ថិដល់នាងក្រមុំអរគុណដល់តាឡិប ទើបគេដើរសំដៅកន្លែងសូត្រធម៌ដែលគេគាត់តែងក្នុងទីគួរសមមួយដោយឡែកក្នុងផ្ទះ សំពះអរគុណដល់ព្រះអាឡស់ ។ រួចពីនោះមក គេទៅគេងលើគ្រែពូកមួយ ក្នុងចិត្តនឹកមិនភ្លេច បំរុងនឹង

ចេញទៅក្នុងវាលខ្សាច់ពេលសងកើត ហើយក៏ដេកលក់ទៅប្រកបដោយចិត្តសប្បាយរីករាយមានសេចក្ដីសង្ឃឹមទុកជាមុន ។

*
* *

ស្អែកឡើងពេលថ្ងៃរះ នាងឡីឡាមិនបានព្រួសបួរដើរសេះដែលអ៊ីស្មាអ៊ីលជិះសេះទៅវាលខ្សាច់ទេ ។ នាងដេកលក់ស៊ប់ឥតយល់សប្តិ ព្រោះអស់កម្លាំងខ្លាំងពេក ។ កាលនាងភ្ញាក់ឡើងផ្លូវថ្ងៃបន្តិច នាងព្រួសបួរសំដីនិយាយ ហើយស្គាល់ច្បាស់ដូចជាសំឡេងមាត់អ៊ីស្មាអ៊ីល ។ នាងពត់ខ្លួនប្រាណ ចេញពីក្នុងឡាំង ឥតមានព្រួយបារម្ភអ្វីទេ ។ នាងស្រាប់តែឃើញតាចាស់ម្នាក់មាឌធំ ដូតធូត ស្លៀកសំពត់លំអដោយគ្រឿងប៉ាក់ដ៏មានតម្លៃ ស្ថិតនៅចំពីមុខ ។ នាងទប់ជើងស្រឡាំងកាំង ។ តាចាស់សំឡឹងនាងមួយស្របក់ រួចបែរទៅរកតាឡិបដែលអង្គុយនៅកៀនមួយស្ងៀមស្ងាត់មិនកំរើក ហើយសួរដោយពាក្យប្រែប្រៀនថា :

– " ស្ត្រីនេះជាអ្វី ? " ។

តែមុនដែលតាឡិបនឹងឆ្លើយ ព្រួសបួរដើរសេះក្នុងទីឆ្ងាយ រួចអ៊ីស្មាអ៊ីលមកដល់មាត់ក្រោល ។ អ៊ីស្មាអ៊ីលឈប់ជើង កាលដែលបានឃើញឪពុក គេមានទឹកមុខស្រពោនយ៉ាងខ្លាំង ។ គ្រាន់តែឃើញអ៊ីស្មាអ៊ីលមកដល់ នាងឡីឡាគ្មានគិតអ្វីណា ក៏ស្ទុះក្តួតទៅរក ហើយសួរទាំងព្រួយថា :

— "ម៉េចទៅអ្នកបង បានឃើញបងស្រីខ្ញុំឬទេ?" ។

អ៊ីស្មាអ៊ីលឆ្លើយប្រាប់ថា:

— "បំណាំងផងព្រះអាឡស់ មិនងាយជនណាអាចជ្រៀតចូលបានឡើយ ។ ត្រូវតែអត់ទ្រាំនៅចំពោះមុខនៃការស៊ូត្រដ៏។ នអំណាចរបស់ព្រះអង្គបុះ ។ ចំថ្ងៃរសៀលបងនឹងប្រើមនុស្សទៅឯវាលខ្សាច់ធ្វើផ្ទៃមួយឲ្យគួរដល់តរុណភាពនឹងរូបសម្បត្តិរបស់បងកំសត់នៃអូន!

នាងឡីឡាមុខឡើងស្លេកស្លាំង ។ នាងទំយាយមិនរួច ទ្រោបលើដៃអ៊ីស្មាអ៊ីល ហើយយំដូចកូនក្មេង ។

ខណៈនោះ អ៊ីស្មាអ៊ីល បែរទៅរកអាពុក ហើយជំពបថា:

— "នាងនេះឈ្មោះឡីឡា ម្ដាយនាងជាប់ជាឈ្លើយនៃពួកពាហានតួរគី បងស្រីនាងស្លាប់នៅកណ្ដាលវាលខ្សាច់" ។

លោកអៃយ៉ាដសំឡឹងមើលទៅកូនរបស់លោកម្ដង សំឡឹងទៅនាងក្រមុំអាក់បម្ដង ។

នាងឡីឡាកំសត់ចេះតែអណ្ដឹតអណ្ដក ។ លោកអៃយ៉ាដនឹកដល់បញ្ញាប់ព្រះអាឡស់ដែលបង្គាប់ថា ត្រូវឲ្យធ្វើជាអ្នកចិត្តល្អសប្បុរស មានមេត្តា ។ លោកលើកដៃក្ដីផ្ទេក១ដោយត្បូងមរកតនឹងត្បូងទទឹម មកច្បូតពុកចង្កាវែងអន្ទាយដូចប្រាក់ ។ លោកមានប្រសាសន៍ថា:

"អ៊ីស្មាអ៊ីល ឯងរើសនាងនារីនេះមកទុកក្នុងផ្ទះអាពុកម្ដាយល្អហើយ ប៉ុន្តែឯងទុកគ្នាឲ្យនៅក្នុងទីនេះ មិនសមរម្យទេ ។ ចាប់ពីពេលនេះទៅ

ត្រូវឲ្យនាងទៅនៅលើផ្ទះយើងជាមួយនឹងប្អូនស្រីឯង ហើយឲ្យស៊ីបាយទឹកតុជាមួយគ្នាផង ។ សូមឲ្យការស្នំគ្រងព្រះរាជ្យសម្រេច ហើយសូមឲ្យគេគោរពសំដីរបស់ព្រះអង្គជានិច្ចកាល !" ។

វាចារបស់លោកអៃយ៉ាដទាំងប៉ុណ្ណោះនេះ សុទ្ធតែជាសំដីដែលចេញមកពីដួងចិត្តដ៏មានមេត្តា ដ្បិតពេកជាមនុស្សដ៏បរិសុទ្ធ ជាអ្នកជួយសង្គ្រោះដោយសុចរិតស្មោះត្រង់ ។

## វគ្គទី ៦

## រស្មីម បេគ អាប់ដាឡ្លះ

ទោះបីជាសម័យមានទុក្ខ ដោយស្រុកកើតចំបាំងកំរងដល ក៏ជីវភាពក្នុងផ្ទះលោកអៃយ៉ាដនៅប្រព្រឹត្តទៅស្រួលគួរសមល្មម នៅជាសុខសប្បាយដល់នាងឡៃឡា ។

ក្នុងគេហស្ថានលោកអៃយ៉ាដ មានក្រុមស្រីៗសម្រាប់មនុស្សថ្នាក់សង្គមជាន់ខ្ពស់ នឹងបែកឯកសិទ្ធិនៃសង្គម ។ លោកនៅមានភរិយាទីពីរ នឹងស្រ្តីខ្វះជាបរិវារ ។ នៅក្នុងផ្ទះមួយទៀតមានសុទ្ធតែធីតារបស់លោក នឹងធីតារបស់ប្អូនលោកដែលអនិច្ចកម្មចោល ហើយលោកទទួលយកមកចិញ្ចឹម ។

នាងឡៃឡាគេទទួលឲ្យនៅក្នុងចំណោមនារីទាំងនោះ ។ ពួកស្រ្តីជាជីដូនមួយនឹងអ៊ីសាអ៊ីល ពេញចិត្តនឹងនាងឡៃឡាជាពន់ពេក ដោយនាងនេះសុតមានប្រាជ្ញានឹងរូបសម្បត្តិបរិបូណ៌ ។ ក្រុមស្រីក្រមុំទាំងអស់

នេះសុទ្ធតែនៅក្មេងៗ អាយុរវាងដប់ប្រាំមួយឬម្ភៃឆ្នាំប៉ុណ្ណោះ ។ ក្នុងវយៈអាយុប៉ុណ្ណោះ តរុណភាពនិងរូបសម្បត្តិនៃស្ត្រី បណ្ដាលមិនឲ្យប៉េះប្រណែនឈ្នានីសគ្នានឹងគ្នាឡើយ រឿងទុក្ខវេទនារបស់នាងក៏សត់ឡីឡា ទៅកកាយទាញករុណាចិត្តចេញពីដួងវិញ្ញាណនៃពួកយុវតីទាំងនោះ ។ ឥឡូវនេះ គឺជាពេលសុខកាយសប្បាយចិត្តនៃនាងឡីឡា ដែលទើបនឹងសោយអនិដ្ឋារម្មណ៍ គឺការអនិច្ចកម្មនៃបងស្រីនាង ។

នាងចរាចរការនេះ ដែលពីដើមធ្លាប់តែនៅហាលថ្ងៃ ហាលខ្យល់ក្នុងជុំរុំដឹគោកគោត មិនដែលនឹកគិតដល់រូបសម្បត្តិម្ដង ងូតទឹកតាមតែប្រទះ ក្នុងជ្រោះ ក្នុងត្រពាំង ឥឡូវនាងបានស្គាល់គ្រឿងតែងកាយពួកស្រីៗ ។ នាងបានស្គាល់ការងូតយ៉ាងសុខុមក្នុងអាង គឺចូលត្រាំកប់ម៉ោងក្នុងអាងពេញដោយទឹកដំរែជាក់ អប់ផ្កាកុឡាប ៗ ស្នានបែបនេះ លុះក្រោកឡើងចេញ នាំឲ្យរូបកាយទន់ល្វន់ គំនិតថ្លា បណ្ដាឲ្យឈាមដំរត់ក្នុងសរសៃតូចធំយ៉ាងប្រពៃ ។ សក់ទៀតក៏មានស្ត្រីបំរើយ៉ាងចំណាប់ក្នុងការផ្ពងសក់ បួង គាប គាស់ ឲ្យត្រឹមត្រូវ ។ នាងបានស្គាល់គ្រឿងលាបទៀត គឺម្សៅក្រអូបអប់ផ្កាម្លិះ ផ្កាកុឡាប មានម្សៅម្យ៉ាងសម្រាប់លីងរោមក្លៀក រោមស្ដូន មានម្សៅសម្រាប់ពត់ចិញ្ចើមសម្រាប់ត្រមង់ព្រុយភ្នែក មានប្រេងសម្រាប់លាបសក់ឲ្យឡើងខ្មៅរលើប ។ សំលៀកបំពាក់ទៀតសោតក៏សុទ្ធតែសូត្រនិងព្រែ, កាលពីមុន នាងស្លៀកពាក់តែសំពត់សាច់គគ្រើម ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតណ្ឌៀ

## លោកសម៉ិន មូត្យនជិមៈ តែង

## លោកវ៉ាយ-ប៊ុក ក្រមការ ប្រៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទីពីរ

មានកាលមួយថ្ងៃ ព្រះអភិរាជភោជៈ ទ្រង់បានសម្រេចក្នុងព្រះទ័យថា នឹងចាត់ឲ្យគេធ្វើរាជាភិសេកទ្រង់ពេញច្បាប់ ទ្រង់ក៏ចូលទៅជិតព្រះបល្ល័ង្កទិព្វព្រមដោយរាជបរិវារ ។ ក្នុងពេលនោះ រូបទេពនិម្មិតទីពីរដែលស្ថិតនៅនឹងព្រះបល្ល័ង្កទិព្វ ពោលថា "សូមព្រះមហាក្សត្រិយ៍ទ្រង់ជ្រាប ព្រះមហាក្សត្រិយ៍អង្គណា អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន លុះតែព្រះមហាក្សត្រិយ៍អង្គនោះ មានព្រះរាជចរិយាសមរម្យស្មារស្មើនឹងព្រះបាទវិក្រមទិត្យ" ។ ព្រះមហាក្សត្រិយ៍ទ្រង់សួរទៅរូបទេពនិម្មិតទីពីរវិញថា "កិត្យានុភាពនៃព្រះបាទវិក្រមទិត្យនោះយ៉ាងណាទៅ?" ។ រូបទេពនិម្មិតនោះ ក្រាបទូលព្រះមហាក្សត្រិយ៍ថា "សូមទ្រង់ព្រះសណ្ដាប់, ទូលបង្គំនឹងក្រាបទូលទ្រង់ក្នុងកាលឥឡូវនេះ៖

អភិរាជវិក្រមទិត្យ ទ្រង់សោយរាជសម្បត្តិនៅប្រទេសអវន្តី; ថ្ងៃមួយទ្រង់បានចាត់ពួកអាមាត្យនៅគ្រប់ទីតំបន់ឲ្យស៊ើបរកអច្ឆរិយវត្ថុ ដែលមាននៅតាមភូមិភាគក្នុងប្រទេស ។ ពួកអាមាត្យក៏បានទៅពិនិត្យភូមិ

ភាគទាំងនោះហើយត្រឡប់មកទូលព្រះមហាក្សត្រិយ៍វិញថា "សូមព្រះអង្គទ្រង់ជ្រាប នៅគិរិចិត្រកុត (Citrakuta) មានវត្តមួយនៅក្បែរនោះ មានដើមផ្កាគ្រប់យ៉ាង ហើយមានទន្លេមួយហូរចំពីមុខវត្ត, បើមានបុគ្គលណាដែលមានចិត្តបរិសុទ្ធចុះទៅមុជទឹកក្នុងទន្លេនោះ រូបបុគ្គលនោះសដូចទឹកដោះគោ, បើបុគ្គលពាលទុច្ចរិត ចុះទៅមុជវិញ ទឹកនោះអាចធ្វើរូបបុគ្គលនោះឲ្យខ្មៅដូចទឹកខ្មៅ(១); នៅទីនោះមានយោគី(២)ម្នាក់សូត្រធម៌ជានិរន្តរ៍ តែងធ្វើកម្មដ្ឋាន, ធ្វើអាមិសបូជានិងធម្មបូជាជានិច្ច តែនាងទេវធីតាមិនសូវពេញចិត្តនឹងព្រះយោគីនោះសោះ" ។

ព្រះបាទវិក្រមទិត្យ ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីរាយការណ៍នោះ ទ្រង់ក៏ស្ដេចទៅកាន់ទីនោះ ទ្រង់ស្រង់ព្រះឧទកៈនៅទន្លេ ហើយទ្រង់ក៏យល់ជាក់ច្បាស់ថាទន្លេនោះ មានទឹកបរិសុទ្ធស្អាតឥតមន្ទិលមែន, ហើយទ្រង់សំដែងព្រះរាជកិរិយាគោរពចំពោះព្រះអាទិទេព រួចទ្រង់ក៏យាងតម្រង់ទៅរកយោគីនោះ ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះជម្រាស់សួរប្រស្នានឹងយោគីនោះថាៈ "យោគី! តើពីកាលណាមក ដែលអ្នកធ្វើអត្តកិលមថានុយោគនេះ (Mortification) ។ ព្រះយោគីក្រាបទូលថាៈ "សូមទ្រង់ព្រះមេត្តាប្រោស! ទូលបង្គំធ្វើតាំងពីខែពិសាខ, ជេស្ឋ, អាសាធ, ស្រាពណ៍, ភទ្របទ, អស្សុជ, កត្តិក, មិគសិរ, បុស្ស, មាឃ,

១ ទឹកខ្មៅប្រហែលដាល់អងភ្លើង ។ ២ យោគី ពួករុក្ខមូលបានធ្វើសមាធិចិត្តដល់ឈានចិត្ត ។

ផល្គុន, ចេត្រ, គឺជាខែប្រមូលប្រមូលហៅថាឆ្នាំ, ឆ្នាំនោះមួយរយឆ្នាំ ហើយទូលបង្គំបានប្រព្រឹត្តធ្វើអត្តកិលមថានយោគ គឺធ្វើខ្លួនឲ្យលំបាក, ទូលបង្គំមិនទាន់បានឃើញនូវទេវធីតាអង្គណាមកប្រោសសោះ ។ ព្រះមហាក្សត្រិយ៍លុះទ្រង់ព្រះសណ្ដាប់នូវសត្តុកថានៃតាបស ទើបទ្រង់ព្រះតម្រិះថា "អញបានថមរូបកាយរបស់អញជានិរន្តរ៍, សេចក្ដីស្លាប់គង់នឹងមានមកជាប្រាកដដល់អញមិនខាន, បើអញលះបង់ជីវិតដើម្បីនឹងធ្វើប្រយោជន៍ជាសាធារណ:, មរណភាពនេះ ហៅថាមរណភាពវិសេស" ។ ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទ្រង់ក៏ប្រកាសកុងព្រះកជហ្វជ័យ ដោយទ្រង់ព្រះវិតក្កទៅកាន់នាងទេវធីតានោះ ហើយក៏ទ្រង់ចាប់ព្រះខ័នថ្ង ទ្រង់រៀបនឹងកាត់ព្រះសិរ ស្រាប់តែនាងទេវធីតាមកដល់ស្ទុះទៅចាប់ព្រះហស្ដព្រះអង្គ ហើយក្រាបទូលថា "សូមទ្រង់កុំកាត់ព្រះសិរ, យើងសប្បាយចិត្តនឹងទ្រង់ណាស់, ចូរទ្រង់សូមមកយើង, ចូរមានព្រះកជឧទ្ធារតាមព្រះកជបំណងចុះ" ។ ព្រះមហាក្សត្រិយ៍ទ្រង់តបទៅនាងទេវធីតាវិញថា "នាងទេវធីតា! យោគីនេះបានព្យាយាមធ្វើបាបរូបកាយមកអស់កាលយូរ; នាងមិនបានអនុគ្រោះចំពោះយោគីនេះ, ឯចំណែកយើង នាងចូលមកប្រោសប្រាណ ម្ដេចក៏យ៉ាងដូចនេះ?" ។ ព្រះនាងទេវីក្រាបទូលព្រះមហាក្សត្រិយ៍ថា "ទុមហាកជក្រមទិត្យ ដូចជាសមាធិធមិចំពោះទៅកាន់មន្ត្រស្រះពិសិដ្ឋ, នាងទេវធីតាត្រូវតេឲ្យ, គ្រូនេះជាករណីយកិច្ចពិតមែន ខ្ញុំម្ចាស់មិនដែលយល់នូវយោគីនេះ ទឹកនាយកខ្ញុំម្ចាស់ជាអារម្មណ៍នៃសមាធិកម្មដ្ឋានណា

មួយទៀយ" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវព្រះវាចានៃព្រះនាងទេវធីតានេះ ទ្រង់ព្រះត្រិះថា ' នាងទេវធីតានេះ មកស្ថិតក្នុងជីវភាពនេះដោយជុំឈើ ឬ ជុំថ្ម; ជីវភាពនេះមកពីការប្រព្រឹត្តិ, ប្រតិបត្តិ(១) " ។ ព្រះមហាក្សត្រិយ៍ដោយទ្រង់មានព្រះរាជបំណងចង់ធ្វើការប្រយោជន៍ជាទៃ, ទើបពោលទៅកាន់នាងទេវធីតាថា " ឱនាងទេវធីតាអើយ, បើព្រះនាងសប្បាយចិត្តនឹងយើង, ហើយដោយហេតុថាយោគីនេះខំប្រព្រឹត្តធ្វើទុក្ខធ្វើបាបខ្លួនគាត់អស់កាលយូរ ថែមទាំងមិនបានសម្រេចផលដ៏ល្អទៀត, សូមព្រះនាងអនុញ្ញាតឲ្យយោគីនេះ ជ្រើសរើសនូវពាក្យសូមដែលព្រះនាងបានបើកឱកាសឲ្យយើងពីមុន" ។ នាងទេវធីតាក៏យល់ព្រមឲ្យយោគីនោះសូមអ្វីតាមប្រាថ្នា ។ ព្រះបាទវិក្រមទិត្យក្រោយដែលបានប្រគល់នូវពាក្យបេ្ដជ្ញានោះទៅយោគី ក៏ទ្រង់វិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ។

រូបទេពនិម្មិតទីពីរបន្ថែមសេចក្ដីថា: បពិត្រព្រះបាទភោជៈ! ទូលបង្គំ បានក្រាបទូលទ្រង់ថា ព្រះបាទវិក្រមទិត្យ ទ្រង់មានព្រះគុណសម្បត្តិពីរយ៉ាងគឺ សប្បុរសធម៌ ១, វីរធម៌ ១, បើគុណសម្បត្តិទាំងពីរយ៉ាងនេះមាននៅក្នុងព្រះទ័យទ្រង់ៗ អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន ។

---

១ នៅទីនេះ គឺជាការពិចារណាដោយសុខុមហើយយល់ជាក់នឹងយល់ពន់ពេក; គេបានញែកជាបីយ៉ាងគឺ: ភាវនា, សិទ្ធិ, ភាវៈ; ប្រតិបត្តិធម៌មកពីភាវនា ហើយភាវៈមកពីប្រតិបត្តិធម៌ ។ វត្ថុអ្វីរស់នៅបាន (ឬមាន) ព្រោះផលនៃភាវនា ។ ប្រហែលជាមានបំណងចង់បន្លំពាក្យភាវៈនឹងភាវនា ។ បើតាមអ្នកបកប្រែ ភាវ-ភាព ប្រែថា បែប, បទ, លំនាំ; ភាវនា ប្រែថា ការចំរើន ។

## និទាននៃរូបទេពនិម្មិតទីបី

ព្រះអគ្គិភជគោជៈ ទ្រង់ប្រេជាក្សត្រ ទ្រង់ឲ្យគេអភិសេក ទ្រង់ឲ្យសោយរាជ្យជាស្ដេចពេញច្បាប់ ហើយទ្រង់ក៏ស្ដេចយាងចូលទៅជិតបល្ល័ង្កទិព្វនោះ ។ ស្រាប់តែរូបទេពនិម្មិតទីបីពោលថា "ឱ! ព្រះអគ្គិភជគោជៈ, សូមទ្រង់ព្រះសណ្ដាប់ទូលបង្គំ; ព្រះមហាក្សត្រិយ៍អង្គណាអាចគង់នៅលើបល្ល័ង្កទិព្វនេះបាន, លុះត្រាតែព្រះមហាក្សត្រិយ៍អង្គនោះ មានព្រះគុណសម្បត្តិដ៏ឧត្ដមដូចព្រះមហាក្សត្រិយ៍វិក្រមទិត្យ" ។ ព្រះអគ្គិភជគោជៈទ្រង់មានព្រះបន្ទូលសួរទៅរូបទេពនិម្មិតទីបីថាៈ "តើព្រះគុណសម្បត្តិដ៏ឧត្ដមនៃមហារាជវិក្រមទិត្យមានអ្វីខ្លះ?" ។ រូបទេពនិម្មិតទីបីទូលថាៈ "ព្រះគុណសម្បត្តិដ៏ឧត្ដមនៃមហាវិក្រមទិត្យ គឺ ខន្តី, ការចំពោះខ្លួន, ចិត្តទឹងទួន, ពលភាព, ប្រាជ្ញា, វីរភាព, នេះជាគុណសម្បត្តិប្រាំមួយយ៉ាង ដែលមាននៅលើបុគ្គលណា អាចធ្វើបុគ្គលនោះឲ្យព្រះអាទិទេពខ្លាចបាន ។ គុណសម្បត្តិទាំងប្រាំមួយយ៉ាងនេះ មានចំពោះមហារាជវិក្រមទិត្យ ។

មានកាលមួយថ្ងៃ, ព្រះមហារាជទ្រង់ព្រះតម្រិះថា "គោតទ្រព្យទឹងពពក បើកាលណាវាមកដល់ តើវាមកពីណា? កាលណាវាទៅវិញតើទៅឯណា? បញ្ហានេះ អញមិនអាចឆ្លើយដោយខ្លួនអញបានទេ ។ ឥឡូវអញមានជោគជ័យជាច្រើន, តែដល់អនាគតតើយ៉ាងណាទៅ? អញក៏មិនអាចដឹងដល់" ។ លុះទ្រង់ព្រះតម្រិះយ៉ាងនេះ, ទ្រង់ក៏មាន

ព្រះរាជបំណងចង់ធ្វើអាមិសបូជាចំពោះព្រាហ្មណ៍, អ្នកក្រ, ស្រ្តី, ក្មេង, ចំពោះអ្នកណាដែលគ្មានគេឧបត្ថម្ភ, អ្នកណាដែលខ្សត់ខ្សោយ ហើយព្រះអង្គយកពន្ធអាករ ពីអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ តែបន្តិចបន្តួច(១) ។ ដើម្បីឲ្យពួកអាទិទេព ទ្រង់សព្វព្រះហឫទ័យនឹងព្រះអង្គ ។ ទ្រង់តែងតាំងពួកព្រាហ្មណ៍ជាអ្នកវិញ្ញូជនចេះដឹងគម្ពីរវេទ, ប្រតិបត្តិធម៌សព្វយ៉ាង, ពលីកម្ម, សូត្រធម៌, ហោម(២), ពលី(៣), លទ្ធិ ។ ចំពោះកិច្ចការខាងអាទិទេព គង្គា, ទ្រង់បានត្រាស់បង្គាប់ឲ្យព្រាហ្មណ៍ម្នាក់ទៅមាត់សមុទ្រ ។ ព្រាហ្មណ៍ទៅដល់ទីនោះធ្វើអញ្ជលីកម្មហើយសូត្រធម៌ផ្សាយទៅរកសមុទ្រ ។ ខណៈនោះ ព្រះឧទកទេវតា (ទេវតាទឹក) បង្ហាញខ្លួនហើយពោលថា: "ព្រាហ្មណ៍! ខ្ញុំពេញចិត្តអនុគ្រោះព្រះបាទវិក្រមទិត្យ ដោយហេតុមហាភជនេះ ប៉ុនប្រសប់គ្រប់យ៉ាង; ពិតមែនតែទ្រង់គង់នៅឆ្ងាយ ខ្ញុំនៅតែស្រឡាញ់ទ្រង់ដរាប ។ ចូរព្រាហ្មណ៍យករតនវត្ថុបួនយ៉ាងទៅថ្វាយព្រះបាទវិក្រមទិត្យ ហើយអ្នកក្រាបទូលព្រះអង្គឲ្យទ្រង់ជ្រាបពីគុណសម្បត្តិ នៃរតនវត្ថុទាំងនេះ ។ អានុភាពនៃរតនវត្ថុទីមួយ ជាអស្ចារ្យពន់ពេក ព្រោះអាចធ្វើឲ្យព្រះស្ងោយ ដែលគ្រាន់តែទ្រង់ព្រះតម្រិះ ក៏មកដល់មួយរំពេច; រតនវត្ថុទីពីរ

---

១ ឧត្តមគតិរបស់ព្រះមហាក្សត្រិយ៍, តាមប្រពៃណីនៃពួកបូរាណជន គឺត្រូវព្រះរាជទានទៅអ្នកទាំងអស់គ្នាជាច្រើន ហើយមិនត្រូវយកពីអ្នកណាមកវិញសោះឡើយ ។ ២ មហាយញ្ញ: ពលិកម្មចំពោះអាទិទេពសំខាន់ ។ ៣ ពលីកម្ម: ចំពោះអាទិទេពតូចតាច គឺបូជាយញ្ញៈតូច ។

បើទ្រង់ចង់បានភោគទ្រព្យអ្វី ក៏បានដូចព្រះបំណង; រតនវត្ថុទីបី បើទ្រង់ព្រះតម្រិះចង់បានកងទ័ពមួយមានរថ, ដំរី, ទ័ពសេះ, ទ័ពថ្មើរជើង ក៏បានតាម; រតនវត្ថុទីបួន បើទ្រង់ចង់បានគ្រឿងអលង្ការអ្វីក៏បានតាមព្រះរាជបំណង" ។

ព្រាហ្មណ៍នោះ ក៏យករតនវត្ថុទាំងបួនវិលត្រឡប់ទៅកាន់ព្រះរាជ-ធានីវិញ ហើយក៏យករតនវត្ថុទាំងនោះទៅថ្វាយព្រះមហាក្សត្រិយ៍; ហើយក្រាបទូលអំពីគុណសម្បត្តិនៃរតនវត្ថុទាំងនោះ ។ ព្រះមហា-ក្សត្រិយ៍មានព្រះបន្ទូលទៅកាន់ព្រាហ្មណ៍ថា: "បណ្ដារតនវត្ថុទាំងបួនឲ្យអ្នកជ្រើសរើសយករតនវត្ថុណាមួយ ទុកជាសិរីវត្ថុរបស់ខ្លួនចុះ" ។ ព្រាហ្មណ៍ក្រាបទូលព្រះមហាក្សត្រិយ៍ថា ទូលព្រះបង្គំ មានបុត្តមួយ, កូនប្រសាស្រីមួយ, ភរិយាមួយ, ទូលបង្គំចង់ពិគ្រោះមើលអ្នកទាំងបីនោះ បើអ្នកទាំងបីយករតនវត្ថុណា ទូលបង្គំក៏យករតនវត្ថុនោះ" ។ ដល់ក្រាបទូលព្រះមហាក្សត្រិយ៍ឲ្យជ្រាបសព្វគ្រប់ប្រការ ព្រាហ្មណ៍ក៏វិលត្រឡប់ទៅកាន់គេហដ្ឋានវិញ ហើយក៏ដំណាលរឿងរ៉ាវនោះប្រាប់ភរិយា, បុត្តនឹងកូនប្រសាស្រី ។ បុត្តពោលថា: "គួរតែយករតន-វត្ថុ ដែលមានដំរីសេះ" ។ ភរិយាពោលថា: "គួរយករតនវត្ថុដែលមានម្ហូបអាហារ" ។ កូនប្រសាស្រីពោលថា: "គួរយករតនវត្ថុដែលមានគ្រឿង មាស-ប្រាក់" ។ ព្រាហ្មណ៍ពោលថា: "រតនវត្ថុណាដែលមានភោគទ្រព្យច្រើន គឺជារតនវត្ថុដែលអញគួរយក" ។ បុគ្គលទាំងបួនមានយោបល់មិនត្រូវគ្នាសោះ ។ ព្រាហ្មណ៍ក៏វិលត្រឡប់ទៅ

គាល់ព្រះមហាក្សត្រិយ៍វិញ ហើយក្រាបបង្គំទូលអំពីរឿងរ៉ាវខាងលើនេះ ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវសុន្ទរកថាព្រាហ្មណ៍ ទ្រង់ក៏ប្រោសព្រះរាជទាននូវគេនវត្ថុទាំងបួនមកព្រាហ្មណ៍ ដើម្បីនឹងឲ្យអ្នកទាំងបួនសប្បាយចិត្ត ។ ព្រាហ្មណ៍នោះ ក៏វិលត្រឡប់មកកាន់គេហដ្ឋានវិញ ដោយចិត្តរីករាយពន់ពេក ។

រូបទេពនិម្មិតទីបី ក្រាបទូលថា: "សូមព្រះមហាក្សត្រិយ៍គោជ:ទ្រង់ជ្រាប: ទូលបង្គំបានក្រាបទូលទ្រង់អំពីឧត្តមភាពនៃមហារាជវិក្រមមិត្យយ៉ាងនេះឯង ។ បើទ្រង់មានព្រះចរិយាដ៏ឧត្តមបែបនេះ ទើបទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន ។ (មានត)

*
* *

## អ្នកធ្វើល្អបានអាក្រក់ អ្នកធ្វើអាក្រក់បានល្អ

សេចក្ដីល្អនៃបរិវារដែលមានសភាពជាអ្នកស្រឡាញ់ស្មោះត្រង់ពិតៗ ខំប្រឹងធ្វើឲ្យ ដួនកាលត្រឡប់ទៅជាទោសអាក្រក់គួរស្អប់ខ្ពើមទៅវិញ, ឯទោសអាក្រក់ប្រត្យក្សលាំងៗ ដែលជនដទៃគេធ្វើឲ្យ ត្រឡប់ទៅជាគុណនាំឲ្យជាទីស្រឡាញ់ពេញចិត្ត. ក៏រីឯព្រះទ័យនៃព្រះរាជាដែលប្រែប្រួលមិននឹងនៅក្នុងភាពតែមួយយ៉ាងនេះ បុគ្គលពិបាកនឹងប្រកាន់កំណត់សំគាល់ណាស់ ដូច្នេះ សេវាធម៌គឺសភាពខំបំរើម្ចាស់ផែនដីនេះ មានសភាពសាំញ៉ាំស្មុគស្មាញក្រៃលែងណាស់ សូម្បីតែព្រះយោគីក៏មិនងាយនឹងបំពេញឲ្យបរិបូណ៌បានឡើយ ។

បញ្ចតន្ត្រ:

**កំណត់ហេតុ ប្រវត្តិការណ៍**

# បុណ្យឆ្លងព្រះវិហារ និង សាលាបឋមសិក្សា

នៅវត្តសិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម

## លោក ចាប-ពិន រៀបរៀង

នៅតាមឆ្នេរទន្លេមេគង្គ (ទន្លេធំ) មានវត្តមួយឈ្មោះ "វត្តសិរីបទុម" ហៅតាមនាមភូមិថា "វត្តអន្លង់ស" ព្រោះជាប្រធាននៃភូមិនេះ ក្នុងឃុំអង្គរបាន ស្រុកកងមាស (កំពង់ចាម) ជាវត្តប្រកបដោយសប្បាយ ៤ យ៉ាង គឺសប្បាយដោយទីសេនាសនៈ ដោយធម៌វិន័យ ដោយបុគ្គលិក-មានសាមគ្គីធម៌ ដោយអាហារគោចរ, មានសាលាបាលីរង, សាលាបឋមសិក្សា ៤ ថ្នាក់ គឺថ្នាក់កុមារដ្ឋាន-បរិវុឌ្ឍដ្ឋាន-អាទិកដ្ឋាន-មធ្យមដ្ឋានទី ១ ជាវត្តបំរើនទាំងផ្លូវធម៌និងផ្លូវលោក និងបំរើនទាំងគន្ថធុរៈ ទាំងវិបស្សនាធុរៈ ដោយគេបែងចែកទីវត្តជា ៣ ភាគ គឺ ២ ភាគខាងមុខជាលំនៅព្រះសង្ឃសិក្សាព្រះបរិយត្តិធម៌, ១ ភាគខាងក្រោយ ដែលមានជម្រំដើមគគីរជារបងខ័ណ្ឌដោយខ្សែក ជាលំនៅគ្រហស្ថអ្នកស្រុកគេនៅក្នុងតូបតូចៗ រក្សាបដិជាគរឧបោសថសីល អតិរេកសីល និងស្ទឹងស្មាធិភាវនា ដោយមានសាលាមួយខ្នង នៅចំកណ្ដាលជាធម្មសភាសម្រាប់អាចារ្យបង្ហាត់សមថវិបស្សនាតាមគម្ពីរវិសុទ្ធិមគ្គ ។

នៅថ្ងៃ ១៥ កើត ១ រោចនិង ២ រោចខែផល្គុន ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៨ ទី ៩ ទី ១០ មីនា ១៩៥៤, វត្តនេះមានកិច្ចធ្វើ

បុណ្យសម្ពោធ (ឆ្លង) ព្រះវិហារដែលសង់ដោយបេតុងអារម៉េ តាមរបៀបទាន់សម័យនិងសម្ពោធសាលាបឋមសិក្សា ។

ដោយទីវត្តនោះធំទូលាយមានទេសភាពស្អាតបាតល្អ មានដើមឈើធំតូចម្លប់ត្រឈឹងត្រឈៃជាជួរៗ រៀងរាយតាមមុខកុដិសាលាទាំងពួង ហើយក្រោមដើមឈើទាំងនោះ មានក្រាលផ្ទាំងស៊ីម៉ងត៍ជាផ្លូវដើររាបទាបល្អ ក៏ជាទីមានលំអគួរជាប់អារម្មណ៍ដល់បណ្ដាជនអ្នកទស្សនា ។

បុណ្យនោះមានរបៀបដូចរៀបរាប់តទៅនេះ ៖

ឧបាសកបំណុះវត្តនេះ តាមធម្មតាគេព្រមព្រៀងចែកគ្នាជា ៤ ក្រុម តាមសង្កាត់នៃភូមិជើងវត្ត គឺ

– សង្កាត់ខាងកើតវត្ត ជាក្រុមទី ១;
– សង្កាត់ខាងត្បូងឈៀងខាងកើត ជាក្រុមទី ២;
– សង្កាត់ខាងត្បូងឈៀងខាងលិច ជាក្រុមទី ៣;
– សង្កាត់ខាងលិចវត្ត ជាក្រុមទី ៤ ។

ក្រុមនីមួយៗ គេតាំងអ្នកមានធនធាន នឹង មានសមត្ថភាពម្នាក់ជាប្រធាន ហើយមានសមាជិកជាច្រើននាក់ សម្រាប់ប្រឹក្សាការបុណ្យទាន, ជាក្រុមនៅក្រោមអធិបតីភាពនៃគណៈកម្មការវត្ត, វេលាធ្វើបុណ្យនេះ គេធ្វើរោងធំ ៤ សម្រាប់ទទួលព្រះសង្ឃ នឹង គ្រហស្ថ មានរបៀបដូច្នេះ :

– ក្រុមទី ១ ធ្វើនៅជ្រុងខាងជើងឈៀងពាយ័ព្យព្រះវិហារ;
– ក្រុមទី ២ ជ្រុងខាងត្បូងឈៀងនិរតីព្រះវិហារ;
– ក្រុមទី ៣ ជ្រុងខាងត្បូងឈៀងអគ្នេយ៍ព្រះវិហារ;

- ក្រុមទី ៤ ជ្រុងខាងជើងឈៀងខាងលិចសាលព្រះវិហារ ។

ពេលទាំង ៤ នោះ សុទ្ធតែរបនាដោយសូត្រក្រុងជាតិ ទង់ជាតិ ទង់សាសនា ព្រះពុទ្ធរូបព្រះបដអង្គធំៗ និងចង្កៀងគោមកែវយ៉ាងល្អៗ គួរជ្រះថ្លា ។ នៅក្រប់មុខពេលធំៗ សុទ្ធតែមានពេលតាំងតូចមួយៗ មានតុកៅអីនិងស្មៀនប្រចាំការ សម្រាប់ទទួលកត់ត្រាប្រាក់ចំណូល ។

មានពេលតាំងធំជាងគេមួយទៀត នៅកណ្ដាលវត្តចំមុខកុដិលោកចៅអធិការ ជារបស់ព្រះសង្ឃសម្រាប់ប្រជុំការធំៗ, ពេលនេះគេរបនាដោយព្រះពុទ្ធរូបព្រះបដផ្ទាំងធំៗ រឿងពុទ្ធប្រវត្តិ និងគ្រឿងសក្ការបូជាយ៉ាងឧឡារិកគួរជ្រះថ្លា ។

នៅគ្រប់ពេលទាំងតូចទាំងធំ សុទ្ធតែមានលំអដោយបជាច្រើនផ្ទាំងតារិកពុទ្ធភាសិត និងខេមរសុភាសិត ជាដំបូន្មានផ្សេងៗ ។

ដោយអំណាចគ្រឿងបក្រមេភ្លើង មានខ្សែវែងអំពូលច្រើនពណ៌ដែលពួកវិស្វករបានដាក់អំពូលភ្លើងតាមសំយាបជុំវិញព្រះវិហារ និងប្រទាក់ទៅគ្រប់ពេលបុណ្យគ្មានសល់មួយអុជបំភ្លឺពេញយប់, បរិយាកាសបុណ្យនេះក៏ភ្លឺវិសេសដូចថ្ងៃ ។

បុណ្យនេះគេធ្វើ ៣ ថ្ងៃ ៣ យប់ គេនិមន្តព្រះសង្ឃពីវត្តផ្សេងៗជាង ៤០ វត្តមកជាបដិគ្គាហក ។ ដើម្បីឲ្យទានបានពេញជាសង្ឃទាន, ព្រះសង្ឃទាំងនោះ ឧបាសកទាំង ៤ ក្រុមគេចាប់ស្លាកបានលោកអង្គណាគេនិមន្តលោកអង្គនោះទៅឆាន់យាគូ ចង្ហាន់ និងគេសង្ឃទានៈនៅពេលគេ ។ ម៉ោង ៧ ព្រឹករាល់ថ្ងៃ គេប្រគេនយាគូ, ម៉ោង ១១ ប្រគេនភត្ត, ម៉ោង ៣

រសៀលប្រគេនភេសជ្ជៈ, ម៉ោង ៨ ល្ងាចរាល់រាត្រីគេជួបជុំគ្នាស្តាប់ព្រះបរិត្ត និងធម៌ទេសនាក្នុងព្រះវិហារ ។ ការសូត្រព្រះបរិត្តក្តី ការសំដែងធម៌ក្តី សុទ្ធតែប្រើឧគ្ឃោសនសព្ទទាំងអស់ ។ រាត្រីទី ១ មានការសំដែងធម៌ ៣ លើក, លើកទី ១ ព្រះមុនីកោសល សោម-ឈុន អធិបតីរងក្រុមជំនុំព្រះត្រៃបិដក, លើកទី ២ ព្រះធម្មិស្សរោ ឯក-ញឹម អតីតវិន័យធរអនុគណស្រុកសូទ្រនិគម (សៀមរាប), លើកទី ៣ ព្រះសាសនមុនី មាស-កង ចៅអធិការវត្តពិកទូរង្ស ភ្នំពេញ ។ រាត្រីទី ២ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។ ពីររាត្រីខាងដើម ជារាត្រីធម៌ទេសនាសុទ្ធ ឥតមានល្បែងល្បាំលាយឡំទេ សូម្បីតែមានចាក់ថាសម៉ាស៊ីនខ្លះដោយឧគ្ឃោសនសព្ទ ក៏ប្រើតែជាសភ្លេងពិណពាទ្យនៅពេលបប់ធម៌មួយលើកៗប៉ុណ្ណោះ ។ ដល់រាត្រីទី ៣ ក្រោយបំផុតនៃកិច្ចបុណ្យ ទើបជារាត្រីសមោសរសុទ្ធ ដោយមានក្រុមចម្រៀងអាយ៉ៃពីភ្នំពេញទៅលេងកំសាន្តចិត្តពួកយុវជន ។

លោកចៅអធិការ និងឧបាសកចំណុះវត្ត បានព្រមព្រៀងគ្នាផ្ទុកផ្តាក់ឲ្យខ្ញុំ (ចាប-ពិន នាយការិយាល័យនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ) ជាអ្នកចាត់របៀបបុណ្យនេះ ព្រោះស្រុកនេះជាមាតុភូមិរបស់ខ្ញុំ ។

របៀបបុណ្យនេះ មានកិច្ចទទួលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជាកិច្ចដ៏ឧឡារិក ដូចរៀបរាប់តទៅនេះ :

ដោយសម្តេចបានណាត់វេលាថា នឹងនិមន្តមកដល់វត្តអន្លង់សនៅម៉ោងជាង ១១ ព្រឹកនៃថ្ងៃទី ៩ មីនា ១៩៥៥, ការចាត់របៀបទទួលក៏បានផ្តើមធ្វើឡើងតាំងពីមុនម៉ោង ១១ ដោយរបៀបដូច្នេះ គឺ

ពីត្រឹមទ្វាររបងវត្តភាគខាងត្បូង ទៅទល់នឹងដំណើរមុខព្រះវិហារចម្ងាយជិតរយម៉ែត្រ មានពុទ្ធបរិស័ទឈរជាពីរជួរអមផ្លូវរថយន្តសម្តេច ៗ ជួរខាងកើតបែរមុខទៅលិច: ពួកសិស្សសាលាបឋមសិក្សាប្រិនរយនាក់ ប្រុសៗ ខាងត្បូង ស្រីៗ ខាងជើង កាន់ទង់ជាតិ ទង់សាសនា ៗ ជួរខាងលិចបែរមុខទៅកើត: ខាងត្បូង ភិក្ខុសាមណេរ, ខាងជើង ឧបាសកឧបាសិកាអ្នកគោរសក់ស្លៀកសពាក់សឈរជួរមុខ, អ្នកស្លៀកពាក់ពណ៌ផ្សេងៗ ឈរជួរក្រោយ យ៉ាងណែនណាន់តាន់តាប់ ៗ ម៉ោង ១១ កន្លះ សម្តេចមកដល់ ៗ កាលរថយន្តចូលដល់ទ្វារវត្ត ទាំងបព្វជិតទាំងគ្រហស្ថ លើកហត្ថប្រណម្យដោយស្ងប់រៀបរយ, លុះរថយន្តបើកសន្សឹមៗ ចូលទៅ ខ្ញុំឈរលើវេទិកានៅយ៉ខាងមុខព្រះវិហារ ប្រកាសដោយឧឃោសនស័ព្ទថា "ជយោ! ព្រះពុទ្ធសាសនា, ជយោ! សម្តេចព្រះមហាសុមេធាធិបតី, ជយោ! សម្តេចព្រះសង្ឃនាយក, (ផ្ទួនៗ) ត្រាតែរថយន្តដល់ជើងដំណើរព្រះវិហារទើបឈប់ ៗ កាលសម្តេចនិមន្តចុះពីរថយន្តឡើងតាមដំណើរព្រះវិហារ, កុមារី ៦ នាក់ឈរអមក្បាលដំណើរ កាន់ពានផ្កាដើរបាចបុប្ផជាតលើកម្រាលពណ៌ក្រហមឆ្អៅ នាំផ្លូវសម្តេចតម្រង់ទៅកើយខាងមុខព្រះវិហារ និមន្តសម្តេចឡើងគង់លើវេទិកា, កាលសម្តេចឡើងគង់ហើយមានថេរ-

ដីកាថា "អាត្មាមានអំណរយ៉ាងជ្រាលជ្រៅចំពោះបដិសន្ថារកិច្ចដែលអស់លោក-អ្នកបានធ្វើចំពោះអាត្មានេះ, សូមឲ្យលោក អ្នកបានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសិរីសួស្តីគ្រប់យ៉ាង; ដោយពេលនេះខ្វះពេក អាត្មាសូមទៀតសំណេះសំណាលបន្តិចចំពោះតែពួកកុមារកុមារី ដោយឃើញថាក្មេងតូច ៗ មានពេលមកប្រជុំជួបនេះតិចណាស់ ពេលរត់លេងច្រើន ៗ អ្នកនាងទាំងឡាយ! អាត្មាមានអំណរណាស់ដែលអ្នកនាងបាននាំគ្នាមកសិក្សាវិជ្ជាអក្សរសាស្ត្រនេះ ចូរអ្នកនាងខំយកចិត្តទុកដាក់រៀនសូត្រឲ្យចេះដឹងទាំងផ្លូវលោកផ្លូវធម៌យ៉ាងម៉ាំមួនទាន់ខ្លួននៅក្មេង ដើម្បីយកវិជ្ជានេះទៅប្រកបជីវភាពនៅវេលាខ្លួនធំឡើង ឲ្យបានបម្រើខ្លួននឹងប្រទេសជាតិ, សព្វថ្ងៃនេះប្រទេសកម្ពុជាបានឯករាជ្យពេញទីហើយ ត្រូវការអ្នកមានចំណេះវិជ្ជាណាស់ ព្រោះចំណេះវិជ្ជានេះហើយដែលអាចញ៉ាំងអនាគតនៃប្រទេសជាតិឲ្យរុងរឿងតទៅ" ។

កាលចប់ថេរដីកាសម្តេច, ពួកកុមារកុមារីទាំងនោះបានច្រៀងប្រគេនពរដោយទំនុក ថាៈ

ខ្ញុំករុណា ទាំងឡាយលើកដៃប្រណម្យ
ទូលថ្វាយបង្គំសម្តេចអគ្គមហាបណ្ឌិត
ដែលគេស្ញប់ស្ញែងពេកពិត
ប្រគេនពរប្រសិទ្ធិ៍, <u>ជាមហាបណ្ឌិតនៃកម្ពុជា</u> (ដ្ឋន) ។

សូមអានុភាពនៃត្រៃរតនា
ជំរាំងក្តាទ្រទ្រង់ឲ្យបានត្រកាល

ទាំងទេពក្នុងបក្រវាឡ

សូមជួយអភិបាល, ឲ្យសព្វៗកាលកុំមើលបណ្ដាំ (ជូន) ។

សូមសម្ដេចមានព្រះជន្មយូរឆ្នាំ

ដើម្បីឧបត្ថម្ភព្រះពុទ្ធសាសនា

ជាម្លប់នៃជាតិខេមរា

ឲ្យរុងរឿងអស្ចារ្យ នឹងមហាក្សត្រាគ្រប់គ្រងផែនដី (ជូន) ។

សាមគ្គីសមគ្គាជាប្រពៃ

ខ្មែរទាំងប្រុសស្រីត្រូវតែបងប្អូន

ប្រទេសជាតិនឹងបានសុខ

បានចំរើនទៅមុខ, យើងត្រូវចាំទុកនូវធម៌សាមគ្គី (ជូន) ។

បន្ទាប់ពីនេះនិមន្តសម្ដេចទៅឆាន់ ។ វេលាម៉ោង ៨ យប់ថ្ងៃនោះ ក្រោយពេលសូត្រព្រះបរិត្ត និមន្តសម្ដេចឡើងគង់លើធម្មាសនៈត្រង់យ៉ាងមុខព្រះវិហារសំដែង ធម៌ទេសនា មុននឹងសំដែង ខ្ញុំបានថ្លែងសុន្ទរកថា មានសេចក្ដីដូចតទៅនេះ :

– សូមឱកាសសម្ដេច,

– ព្រះករុណាគ្រប់ព្រះអង្គ,

– អស់លោក-អ្នកសប្បុរសទាំងឡាយ,

ដើម្បីថ្លែងប្រវត្តិវត្តនេះ នឹងពិធីបុណ្យនេះ ដូចតទៅ:

វត្តនេះ ផ្ដើមសាងឡើងក្នុងវាង ព.ស. ២៤៩០ ជាយ គិតមកដល់ឆ្នាំនេះ ប្រមាណជា ៤០ ជាយឆ្នាំ, នាមដែលតាឱកក្នុងផ្ទការជា

"វត្តសិរីបទុម" ប្រែថា "វត្តមានឈូកដ៏មានសិរី" ដោយសន្មត តាមទីវត្តនេះកាលខាងដើម ដែលមានព្រែកមានទឹកខួបប្រាំងវស្សា មានឈូកដុះពាសពេញ មានផ្កាផ្លែជានិច្ច, នាមក្រៅផ្លូវការថា "វត្តអន្ទង់ស" តាមឈ្មោះទីកន្លែងនេះ ព្រោះមុនពេលសាងវត្តនេះ នៅមាត់ព្រែកជ្រុងញៀសានវត្ត មានឈើធំមួយដើមជាឈើអ្នកស្រុកតែងបូជា, មានដំណាលថា យប់មួយនោះ ជនម្នាក់យល់សប្តិឃើញតាចាស់ម្នាក់ប្រាប់ថា "បើចង់បានអន្ទង់ស ចូរទៅយកនៅព្រែកក្បែរដើមឈើនោះចុះ" ព្រឹកឡើងជននោះទៅនេសាទក្នុងទីនោះក៏បានអន្ទង់មួយមានសម្បុរសមែន, ក្រោយពីនោះមកអ្នកស្រុកនាំគ្នាហៅទីនោះថា "អន្ទង់សៗ" រហូតដល់សព្វថ្ងៃ ។ កាលមិនទាន់មានរឿងទាក់ទងដោយអន្ទង់ស ភូមិជើងវត្តនេះដោយហេតុមានដើមរកាមួយដើមធំកំបុតចុង គេហៅថា "ភូមិរកាកំបុត" ប៉ុន្តែដោយឈ្មោះនេះជាទំនាស់នឹងជាតិពាមដែលនៅក្នុងភូមិនោះផង ដោយទីនោះមានដើមពោធិ៍ធំមួយដើមស្រិតទៅក្នុងទន្លេធំផង អ្នកស្រុកក៏ផ្លាស់ឈ្មោះរកាកំបុត ទៅជាភូមិពោធិ៍ស្រិតវិញ, ហើយដោយពាក្យថាពោធិ៍ស្រិតជាទំនាស់នឹងអធ្យាស្រ័យខ្មែរ ក៏ត្រឡប់ជាបាត់ឈ្មោះនោះទៅកើតឈ្មោះថា "អន្ទង់ស" ឡើងជាឈ្មោះភូមិជើងវត្តនេះទាំងមូល តាមប្រផ្នូលដូចពោលខាងដើម តាំងពីពេលសាងវត្តនេះរហូតដល់សព្វថ្ងៃ ។

វត្តនេះ តាំងពីផ្ដើមសាង រវាងពី ព.ស. ២៤៥០ ប្លាយ មកដល់ ព.ស. ២៤៩៧ នេះមានចៅអធិការ ៣ រូប គឺ

– ចៅអធិការទី ១ ព្រះនាម សូរ-គឹម ដែលលោកគ្រូបណ្ឌិតឯក

នឹងលោកកក្តីផ្លាសុខ ជាអ្នកផ្តើមសាងវត្តនេះបាននិមន្តពីវត្តអូរខ្សាច់ស្រុកស្រីសុន្ធរមក ។ លោកគ្រូអង្គនេះបានផ្តើមសាងព្រះវិហារនេះដោយគ្រឿងឈើជញ្ជាំងប្រិតាំ នឹងកុដិសាលាខ្លះ ហើយលោកសុគតទៅ ;

— ចៅអធិការទី ២ ព្រះនាម អ៊ុក-ទឹម លោកបានសាងកុដិស.លាបន្ថែមជាច្រើន ជាមួយខ្ញុំព្រះករុណាខ្ញុំបាទ (ចាប-ពិន) កាលនៅជាបណ្ឌិត ដែលបានសាងសាលាបាលីនេះមួយខ្នង មានជាន់ពីរដោយឥដ្ឋ បានជួយបង្ហើយសាលាបឋមសិក្សាមួយខ្នង មានជាន់មួយដោយឥដ្ឋ បានក្រាលឥដ្ឋពណ៌ព្រះវិហារនេះ ។ល។ នឹងជាមួយព្រះធម្មិស្សរោ ឯក-ញឹម ដែលបានសាងកុដិមួយខ្នង នឹងទីធ្វើសមាធិ ហើយលោកគ្រូ អ៊ុក ទឹម ចាកសិក្ខាបទទៅ ;

- ចៅអធិការទី ៣ ព្រះនាម សម្រិទ្ធ ជាចៅអធិការបច្ចុប្បន្ន បានសាងជញ្ជាំងព្រះវិហារជាថ្មី មានយ៉ ៤ ទិស នឹងខឿនព្រះវិហារដោយឥដ្ឋនឹងបេតុងអារម៉េ ដោយបែកមុខឲ្យទាយកអ្នកមានសទ្ធាម្នាក់ៗធ្វើតាមល្វែងតាមផ្ទាំង ព្រមទាំងគូរគំនូររឿងពុទ្ធប្រវត្តិយ៉ាងល្អ សឹងមានចារិកឈ្មោះអ្នកសាងគ្រប់ផ្ទាំងនោះៗស្រាប់ ព្រមទាំងបានសាងសាលាធម្មសភា សាលាបឋមសិក្សាដោយគ្រឿងឈើ ។ល។ ដែលសារុបធ្វើបុណ្យសម្ពោធក្នុងវេលានេះ ។

ករណីយកិច្ចដែលលោកចៅអធិការទី ៣ បានធ្វើឲ្យវត្តនេះបានចម្រើនមានច្រើនបែប, បែបដែលប្លែកពីវត្តធម្មតា គឺលោកបានធ្វើរបងវត្តដោយដាំដើមយុទ្ធកា មានបន្ទាចាក់ស្រះជិតស្និទ្ធជុំវិញវត្ត មានទ្វារ

ហាក់ស្រាក សម្បីតែភិក្ខុ សាមណេរ ឬ ឧបាសកដើរវត្ត តែហួសពេលម៉ោងមិនអាចចេញចូលរហោតរហូតបាន ។ល។

ឧបាសកដើរវត្តជ្រះថ្លា ចំពោះករណីយកិច្ចរបស់លោកចៅអធិការនេះ បានចំណាយធនធានកសាងវត្ត នេះតាមកម្លាំងសទ្ធារៀងខ្លួន ហើយបានធ្វើបុណ្យសម្ពោធនេះជាការបន្ថែមបុណ្យឡើងទៀត ។

បុណ្យនេះ ដោយសារសម្តេចនឹងព្រះករុណាគ្រប់អង្គ ព្រមទាំងអស់លោក អ្នកសប្បុរសនៅស្រុកជិតឆ្ងាយបាននិមន្ត បានអញ្ជើញមកជាអធិបតី មកជួយអនុមោទនាផង ក៏បានជាបុណ្យឧឡារិកអធិកអធំគួរជ្រះថ្លាក្រៃពេក ។

ក្នុងនាមឧបាសកដើរវត្តនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រគេន សូមជូនពរសព្ទសាធុការ ចំពោះសម្តេច, ព្រះករុណាគ្រប់អង្គ នឹងអស់លោក-អ្នកសប្បុរស សូមឲ្យបានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ នឹងសិរីសួស្តីជ័យមង្គលគ្រប់ប្រការ សព្វទិវាកាត្រីកុំបីមានចន្លោះឡើយ !

បន្ទាប់ពីសូត្ររកថា ខ្ញុំអាពធនាសម្តេចសំដែងធម៌សមគួរតាមកាលវេលា ។ ពេលនោះក៏មានបរិយាកាសរីករាយយ៉ាងក្រៃលែង ។

ព្រឹកឡើងថ្ងៃ ២ កេច ផល្គុន (១០ មីនា ១៩៥៥) និមន្តព្រះសង្ឃដារឆ្ងន់ ជាកិច្ចបង្ហើយបុណ្យត្រឹមប៉ុណ្ណេះ ។